ខុមហ្វ្រែល COMFREL

ព្រឹត្តិបត្រ ខុមហ្វ្រែល

# អ្នកឃ្លាំមើល

NEAK KLOAMMEUL

លេខ ៣៤ ឆ្នាំទី១០ ចេញថ្ងៃទី១៥ ខែមេសា ឆ្នាំ២០០៧

## កងកម្លាំងមានអព្យាក្រឹត ពិតជាធ្វើឱ្យការបោះឆ្នោត គ្មានការភ័យខ្លាច




## មាតិកា


- *អធិប្បាយលេខនេះ :* ការអង្កេតរបស់ខុមហ្វ្រែលលើការវិវត្តបរិយាកាសនយោបាយ........១
- ការផ្លាស់ប្តូរបក្ស គឺជាប្រពៃណីអ្នកនយោបាយនៅពេលជិតបោះឆ្នោត........៣
- សង្ខេបលទ្ធផលការងារសំខាន់ៗរបស់ខុមហ្វ្រែល ឆ្នាំ២០០៧........៥
- ការវាយតម្លៃរបស់យុវជនអំពីការបំពេញរបស់រាជរដ្ឋាភិបាលកម្ពុជា ឬគណបក្សនយោបាយជាប់ឆ្នោត........៩
- ឃ្លាំមើលសភា និងតំណាងរាស្ត្រសំរាប់ខែធ្នូ ២០០៧ - កុម្ភៈ ២០០៨........១១
- កាលប្បវត្តិព្រឹត្តិការណ៍សំខាន់ៗ ពីពាក់កណ្តាលខែធ្នូ ឆ្នាំ២០០៧ ដល់ពាក់កណ្តាលខែមីនា ២០០៨........២០


អ្នកឃ្លាំមើល : ការផ្សព្វផ្សាយរបស់គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា

<u>**អធិប្បាយលេខនេះ**</u>

# ការអង្កេតរបស់ខុមហ្វ្រែលលើការវិវត្តបរិយាកាស នយោបាយក្នុងដំណាក់កាលមុនការបោះឆ្នោតឆ្នាំ ២០០៨

*ដោយ ខុមហ្វ្រែល-អ្នកឃ្លាំមើល*

**គណៈកម្មាធិការ ខុមហ្វ្រែល** បានសង្កេតឃើញថា បរិយាកាសជាទូទៅគិតមកដល់ពេលនេះ មុនការបោះឆ្នោតជាតិឆ្នាំ ២០០៨ **នៅបន្តសភាពល្អគ្រាន់បើជាងការបោះឆ្នោតលើកមុនៗ**។ ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ នៅឆ្នាំ២០០៧ (ក្នុងដំណាក់កាលត្រៀមការបោះឆ្នោតឆ្នាំ ២០០៨)[១] មាន**ករណីគំរាមកំហែង ទៅលើសកម្មជនគណបក្សនយោបាយ មានការកើន ឡើងទ្វេដង និង ការកើនឡើងនូវបញ្ហាអសន្តិសុខផ្ទាល់ខ្លួនបើប្រៀប ធៀបនឹងឆ្នាំ២០០៦[២] បើទោះបីជា របាយការណ៍រាជរដ្ឋាភិបាល បង្ហាញពីការធ្លាក់ចុះចំនួនក៏ដោយ**។ សកម្មជនគណបក្សនយោបាយមួយចំនួនដែល **ភាគច្រើន ជាសកម្មជនគណបក្សមិនកាន់អំណាច** បានទទួលរងនូវការ**គំរាមកំហែង**ដូចជាគណបក្សសមរង្ស៊ី ២៩ករណី គណបក្ស ហ៊្វុនស៊ិនប៉ិច ២ ករណី គណបក្សនរោត្តមរណឫទ្ធិ ១២ ករណី គណបក្សសិទ្ធិមនុស្ស ៦ករណី និងគណបក្សផ្សេងៗទៀត ២ករណី។ យោងតាមការសង្កេតរបស់ **ខុមហ្វ្រែល** ករណីទាំងនេះភាគច្រើនកើតឡើងនៅ ក្នុងខេត្តបន្ទាយមានជ័យ កំពង់ចាម កំពង់ឆ្នាំង កំពង់ស្ពឺ កំពង់ធំ កណ្ដាល និងបណ្ដាខេត្តមួយចំនួនខ្លះទៀត។

ទោះបីជាពុំឃើញមានករណីឃាតកម្ម និងអំពើហិង្សាធ្ងន់ធ្ងរទៅលើអ្នកនយោបាយ និងសកម្មជនគណបក្ស យ៉ាងណាក៏ដោយ ក៏ការសង្កេតរកឃើញថា **ការរារាំង និងរំខានសកម្មភាពនយោបាយនៅមានជាបន្ត**។ ករណីទាំងនោះ រួមមាន **ករណីទម្លាក់ស្លាកគណបក្សនយោបាយ** ចំនួន ១២ ករណី[៣] ជាពិសេស គណបក្ស នរោត្តមរណឫទ្ធិ និង គណបក្សសិទ្ធិមនុស្សដែលជាគណបក្សទើបបង្កើតថ្មី។ ប៉ុន្តែរហូតមកដល់ពេលនេះ គេពុំទាន់ឃើញមានការអង្កេត ឬការដោះស្រាយបញ្ហានេះ ឱ្យមានប្រសិទ្ធភាពនៅឡើយ ដោយនៅមានការទម្លាក់ការទទួលខុសត្រូវ ក្នុងការដោះស្រាយបញ្ហានេះ រវាងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (**គ.ជ.ប**) និងអាជ្ញាធរមានសមត្ថកិច្ច។

ទន្ទឹមនឹងគ្នានេះ **ការអនុវត្តសេរីភាពបញ្ចេញមតិ**របស់គណបក្សនយោបាយ (មិនមែនជាគណបក្សកាន់អំណាច) និងអង្គការសង្គមស៊ីវិល តាមរយៈវេទិកា ការហែក្បួនដោយសន្តិវិធី ការចែកផ្សាយព័ត៌មាននៅតាមទីផ្សារ **នៅបន្តជួបឧបសគ្គ** ដូចជាការរារាំងមិនឱ្យប្រើប្រាស់ទីកន្លែង ហើយពេលខ្លះមានការបង្ក្រាបពីសំណាក់អាជ្ញាធរ។ របាយការណ៍ អង្គការសិទ្ធិមនុស្ស[៤] បានរកឃើញថា មានករណីជាច្រើន ដែលអាជ្ញាធរមូលដ្ឋានបានប្រើប្រាស់ឥទ្ធិពលរបស់ខ្លួនក្នុងការព្រមានម្ចាស់ទីកន្លែង មិនឱ្យគណបក្សនយោបាយ ឬអង្គការសង្គមស៊ីវិលប្រើប្រាស់។ ម្ចាស់ទីកន្លែងឯកជនខ្លះ បានទទួល រងការគាបសង្កត់ផ្នែកស្មារតី ដោយមិនហ៊ានជួល ទីកន្លែងឱ្យអង្គការ ឬគណបក្សនយោបាយ រៀបចំវេទិកា ឬការជួបប្រជុំធំៗ។ ជាក់ស្តែងមានករណីអាជ្ញាធរ មូលដ្ឋាន**មិនផ្តល់ទីកន្លែងទីសាធារណៈ ឬរារាំងអ្នករៀបចំ ឬម្ចាស់ទីកន្លែង** ក្នុងការធ្វើសកម្មភាពដើរក្បួន ដោយសន្តិវិធី ជួបប្រជុំពិភាក្សាធំៗ ដូចជា ករណីកើតមានឡើងចំពោះគណបក្សសិទ្ធិមនុស្ស ដែលធ្លាប់បានស្នើសុំបរិវេណវាលព្រះមេរុ ឬសួនច្បារផ្សារចាស់ ឬវត្តភ្នំ ដើម្បីរៀបចំវេទិកាពិភាក្សាបញ្ហាប្រេងសាំងឡើងថ្លៃជាដើម។

លើសពីនេះទៅទៀត សកម្មភាពខ្លះ របស់**ចលនាយុវជនក្នុងកិច្ចការនយោបាយត្រូវបានរារាំងដោយអាជ្ញាធរ** ផងដែរ។ ឧទាហរណ៍ អាជ្ញាធរក្នុងខេត្តបន្ទាយមានជ័យ ធ្លាប់បានហាមឃាត់ចលនាយុវជន គណបក្ស សមរង្ស៊ី ក្នុងការធ្វើសកម្មភាពអនាម័យមូលដ្ឋាន កាលពីថ្ងៃទី ៧ ខែ មករា ឆ្នាំ ២០០៨។ មានក្រុមយុវជន ប្រមាណជិត ២០០ នាក់ ដែលចង់ជួបជុំគ្នាជជែក ពិភាក្សាពីកម្មវិធីនយោបាយ ក្នុងការបង្កើតការងារជាមួយមន្ត្រីជាប់ឆ្នោត ក្នុងវេទិកាសម្លេងម្ចាស់ឆ្នោត សម្របសម្រួលដោយខុមហ្វ្រែល នៅខេត្តកណ្តាល នាថ្ងៃទី ២៣ ខែ មករា ឆ្នាំ ២០០៨ បានពន្យារពេលដំណើរការ ដោយសាររូបភាពនៃឥទ្ធិពល អាជ្ញាធរទៅ លើអ្នកគ្រប់គ្រង

---

១ ស្ថានភាពសិទ្ធិមនុស្ស ២០០៧ លេខ៧ ឆ្នាំទី៧ បោះពុម្ពផ្សាយខែ មករា ឆ្នាំ ២០០៨ របស់សមាគមអាដហុក។

២ ឆ្នាំ ២០០៦ មាន ២៤ ករណី។ ឆ្នាំ ២០០៧ មាន ៥៥ ករណី។

៣ ជាចំនួនករណី ដែលអ្នកសង្កេតការណ៍ខុមហ្វ្រែល បានទទួលព័ត៌មាន នឹងចុះប្រមូលព័ត៌មានបន្ថែម។ ករណីនេះភាគច្រើន កើតនៅក្នុងទីក្រុងភ្នំពេញ ខេត្តកណ្តាល កំពត កំពង់ឆ្នាំង និងបន្ទាយមានជ័យ។

៤ របាយការណ៍សិទ្ធិមនុស្សឆ្នាំ ២០០៧ របស់គណៈកម្មការសិទ្ធិមនុស្សអាស៊ី។

ទីកន្លែងសាលារៀនមិនហ៊ានអនុញ្ញាត ។ រីឯនៅ ទីក្រុងភ្នំពេញ យុវជន ប្រមាណ ១០ នាក់ពី គណបក្សសិទ្ធិមនុស្ស ត្រូវបានឃាត់ខ្លួន ដោយសន្តិសុខផ្សារអូរឫស្សី ដោយគ្រាន់តែពួកគេធ្វើសកម្មភាពចុះ សម្ភាសន៍ជាមួយអ្នកលក់ដូរ ។

ការសង្កេតផ្សេងទៀតក៏បានរកឃើញផងដែរថា **មន្ត្រីរាជការស៊ីវិល និងកងកម្លាំងប្រដាប់អាវុធដែលមានឋានៈខ្ពស់ចាប់ពីប្រធានការិយាល័យ រហូតដល់អគ្គនាយកបាន និងកំពុងចូលរួមធ្វើសកម្មភាព ចុះពង្រឹងគណបក្សកាន់អំណាច ពិសេសគណបក្សប្រជាជនកម្ពុជា** នៅតាមមូលដ្ឋាន និងការចែកអំណោយ ដែលបេសកកម្មនោះ ធ្វើឡើងនៅក្នុងម៉ោងធ្វើការក៏មាន ហើយបានផ្សព្វផ្សាយតាមទូរទស្សន៍ និងវិទ្យុ និងសារព័ត៌មាន ។ បើគ្រាន់តែសង្កេតក្នុងរយៈពេល មួយខែ[៥] មានមន្ត្រីរដ្ឋបាល និងកងកម្លាំងប្រដាប់អាវុធបានចុះពង្រឹងគណបក្សចំនួនច្រើនជាង **៦០** បេសកកម្មក្នុងម៉ោងធ្វើការ ហើយយ៉ាងហោចណាស់មាន ១ករណីដែលគំរាមកំហែងដល់សកម្មជនគណបក្សផ្សេងនៅមូលដ្ឋាន[៦] ។ សកម្មភាព នេះជាការ **រំលោភលើច្បាប់ ស្តីពីគណបក្សនយោបាយ**មាត្រា១៥ ដែលបានចែងថា *"...មន្ត្រីតុលាការ កងយោធពលខេមរភូមិន្ទ និងកងកម្លាំង នគរបាល...អាចចូលជាសមាជិកគណបក្សនយោបាយ...តែមិនត្រូវធ្វើសកម្មភាពប្រឆាំង ឬគាំទ្រគណបក្ស ... ។"*

បើទោះបីគណបក្សមិនកាន់អំណាច មានការលំបាកយ៉ាងខ្លាំងក្នុងការប្រើប្រាស់ទីកន្លែងអគាររដ្ឋ ដើម្បីរៀបចំកិច្ចប្រជុំនានា ប៉ុន្តែគណបក្សកាន់អំណាចពិសេសគណបក្សប្រជាជនកម្ពុជា មានលទ្ធភាពប្រើប្រាស់ទីកន្លែងអគាររដ្ឋ និងថវិកាជាតិ ដើម្បីបំរើផលប្រយោជន៍នយោបាយរបស់ខ្លួនដែរ ។ ជាក់ស្តែង **ថ្នាក់ដឹកនាំគណបក្សប្រជាជនកម្ពុជាបាន អំពាវនាវថា បើសមាជិកគណៈកម្មាធិការនាយករបស់គណបក្សជំទាស់(គណបក្សសមរង្ស៊ី) ចាកចេញពីគណបក្សនេះ នោះនឹងមានការ ផ្តល់តំណែងទីប្រឹក្សារាជរដ្ឋាភិបាល ដែលតំណែងនេះមានឋានៈស្មើនឹងរដ្ឋមន្ត្រី ឬរដ្ឋលេខាធិការ ដែល អាចនឹងទទួលបាន ប្រាក់បៀវត្សរ៍រដ្ឋ**[៧] ។ ករណីនេះ បាន**រំលោភទៅលើគោលការណ៍បោះឆ្នោតដោយត្រឹមត្រូវ និង យុត្តិធម៌ ដែលប្រើប្រាស់ ថវិការដ្ឋ ដើម្បីបំរើនយោបាយគណបក្សមួយ** ។ ទន្ទឹមនឹងនោះក៏មានការចោទប្រកាន់ពីសំណាក់ ថ្នាក់ដឹកនាំគណបក្សប្រជាជនកម្ពុជាថា **មានការគំរាមកំហែងទៅលើអ្នកដែលធ្វើចលនាអូសទាញប្រមែប្រមូលអ្នកគាំទ្រ គណបក្ស ផ្សេងឱ្យមកគាំទ្រ គណបក្សប្រជាជនកម្ពុជាវិញ** នៅក្នុងខេត្តកំពង់ធំ និងខេត្តតាកែវ ហើយបានស្នើឱ្យមានការស៊ើបអង្កេតស៊ីជម្រៅមួយ[៨] ។ ទោះបីជាយ៉ាងណាក៏ដោយ ការព្រមាននេះបាននាំឱ្យមានការចេញដីកា**បង្គាប់ឱ្យចូលខ្លួនមកបំភ្លឺ** ពីសំណាក់តុលាការខេត្ត កំពង់ធំ ទៅលើមេឃុំគណបក្សសមរង្ស៊ីម្នាក់ និងបណ្តាញគណបក្ស នេះ ចំនួន ២ នាក់ ផ្សេងទៀត ដោយពីបទ***ពង្រត់ និងបង្ខាំងមនុស្សខុសច្បាប់*** និងការចាប់ខ្លួនបុរសម្នាក់នៅ ក្នុងខេត្តតាកែវបញ្ជូនមកកាន់ ក្រសួងមហាផ្ទៃ ដើម្បីសាកសួរព័ត៌មាន[៩] ។ ការណ៍នេះអាចជា ការគំរាមកំហែង បំភិតបំភ័យបំបាក់ស្មារតីដល់សកម្មជន គណបក្សសមរង្ស៊ី ។

គណបក្សនយោបាយសំខាន់ៗមួយចំនួន មិនមែនគណបក្សប្រជាជនកម្ពុជា មានលទ្ធភាពប្រើប្រាស់ស្ថានីយ៍វិទ្យុឯកជនសំខាន់ៗមួយចំនួនដូចជា FM ១០៥ FM ៩០ FM ៩០.៥ FM ៩៣.៥ ជាដើម ។ ស្ថានីយវិទ្យុខាងលើនេះ បានគោរពគោលការណ៍ផ្តល់ការលក់ម៉ោងឱ្យគណបក្សផ្សេងៗបានទិញម៉ោងក្នុង តម្លៃប្រហាក់ប្រហែលគ្នា បើទោះបី កម្មវិធី របស់គណបក្សនយោបាយនីមួយៗមានព័ត៌មាន និងមតិទិតៀន គ្នាទៅវិញទៅមក ក្នុងស្ថានីយ៍វិទ្យុតែមួយ ។ ប៉ុន្តែការ ផ្សាយរបស់ទូរទស្សន៍ទាំង ៧ និងវិទ្យុមួយចំនួនបាន បន្តផ្សាយលម្អៀងទៅរកគណបក្សប្រជាជនកម្ពុជានោះ ហើយក៏មិនបើកចំហ លក់ម៉ោងពេលឱ្យកម្មវិធីរបស់ គណបក្សផ្សេងៗទៀត ដែរ ។ ទន្ទឹមនឹងនេះផងដែរ សារព័ត៌មានដែលមាននិន្នាការ ប្រឆាំងនឹងរដ្ឋាភិបាលមួយ ឈ្មោះ **ស្រឡាញ់ខ្មែរ** ក៏បានចុះចូលជាមួយ គណបក្សប្រជាជនកម្ពុជាផងដែរ (ដូចលេខ ៨) ។



ការអង្កេតរបស់ ខុមហ្វ្រែល ដោយឡែកចំពោះទូរទស្សន៍ជាតិកម្ពុជា

---

៥ គិតពីថ្ងៃទី ៨ ខែ កុម្ភៈ ដល់ថ្ងៃទី ៨ ខែ មីនា ឆ្នាំ ២០០៨ ផ្សាយតាមរយៈទូរទស្សន៍ ទទក ។

៦ ការផ្សាយរបស់វិទ្យុ ធំ ១០៥ កម្មវិធីពន្លឺភ្លើងទៀន នៅថ្ងៃទី ០១ ខែ មីនា ឆ្នាំ ២០០៨

៧ ខ្លឹមសារដកស្រង់ចេញពីការចាក់ផ្សាយសុន្ទរកថារបស់នាយករដ្ឋមន្ត្រី របស់ទូរទស្សន៍ជាតិកម្ពុជា នាថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ២០០៨ ។

៨ សម្តេច ហ៊ុន សែន មានប្រសាសន៍នៅក្នុងខេត្តព្រៃវែង ថ្ងៃទី ១៧ ខែ មីនា ឆ្នាំ ២០០៨ ចាក់ផ្សាយតាមទូរទស្សន៍ ទទក ។

៩ យោងតាមរបាយការណ៍បឋមរបស់បណ្តាញ ខុមហ្វ្រែល នៅក្នុងខេត្តទាំងពីរ កាលពីថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ២០០៨ ។ ខុមហ្វ្រែល នឹង បន្តស៊ើបអង្កេតករណីនេះជាបន្តទៀត ។

*តទៅទំព័រទី ១៣*

# ការផ្លាស់ប្តូរបក្ស គឺជាប្រពៃណីអ្នកនយោបាយនៅពេលជិតបោះឆ្នោត

ចលនានៃការចាកចេញ ការផ្លាស់ប្តូរ ឬការរត់ទៅរត់មកឆ្លេឆ្លាៗពីគណបក្សមួយទៅគណបក្សមួយទៀត របស់អ្នកនយោបាយ ជាពិសេសអ្នកនយោបាយខ្មែរនៅពេលជិតបោះឆ្នោតក៏រិតថ្នាក់ជាតិម្តងៗ ត្រូវបានក្រុមអ្នកតាមដាន និងវិភាគស្ថានការណ៍នយោបាយស្រុកខ្មែរ ចាត់ទុកថាជាប្រពៃណី ឬជាទំលាប់របស់ក្រុមអ្នកនយោបាយខ្មែរ មួយចំនួនទៅហើយ។ តាមការសង្កេតក្នុង រយៈពេលប្រមាណពីរបីខែចុងក្រោយនេះ មានអ្នកនយោបាយជាន់ខ្ពស់នៃ បណ្តាគណបក្សនយោបាយនានាៗ បានលាលែងពីគណបក្សដើមរបស់ខ្លួន ហើយទៅចុះចូលជាមួយគណបក្សដទៃ។ ក្នុងនោះ គឺមានភាគច្រើនគឺ ការចាកចេញពីគណបក្សហ៊្វុនស៊ិនប៉ិច និងគណបក្សសម រង្ស៊ី មកគណបក្សប្រជាជនកម្ពុជា និងក៏មានការចាកចេញពីគណបក្សសម រង្ស៊ីមកគណបក្សហ៊្វុនស៊ិនប៉ិច ផងដែរ។ អ្នកដែលចាកចេញពីបក្សចាស់ចូលបក្សថ្មីនេះ ខ្លះមានតួនាទី និងមុខតំណែងខ្ពស់រហូតដល់ជាតំណាងរាស្ត្រ រដ្ឋមន្ត្រី រដ្ឋលេខាធិការ និងមួយចំនួនតូចជាមន្ត្រីរដ្ឋបាល និងអ្នកបច្ចេកទេស។

ជុំវិញការចាកចេញទៅមកទៅមកនេះ មានមតិវិភាគពីរបានលើកឡើងថា ការចាកចេញនេះដោយសារ សាមីខ្លួនមិនពេញចិត្ត ឬមានបញ្ហាជាមួយការដឹកនាំរបស់គណបក្សចាស់របស់ខ្លួន ឬដោយសារការអស់សង្ឃឹមក្នុងការទទួលបាននូវលាភសក្ការៈពីគណបក្សខ្លួន ឬដោយសារភាពទន់ខ្សោយរបស់អ្នកដឹកនាំនៃគណបក្ស។ល។ ហើយក៏មាន ការសង្ស័យថា ការចេះតែមានការចាកចេញពីគណបក្សមួយទៅគណបក្សមួយទៀតជាហូរហែ នោះដោយសារ គណបក្សនោះមានការធ្លាក់ចុះប្រជាប្រិយភាព ឬគណបក្សនោះមានបញ្ហាបែកបាក់ផ្ទៃក្នុងជាដើម។ តែទន្ទឹមនេះក៏មាន មតិមួយទៀតលើកឡើងថា ការចាកចេញពីគណបក្សចាស់ទៅគណបក្សថ្មីនោះគឺដោយសារមានការអូសទាញដោយ ប្រើប្រាស់គ្រប់មធ្យោបាយពីគណបក្សម្ខាងទៀត ដូចជាការទិញទឹកចិត្ត ការផ្តល់តួនាទីឋានៈ ឬការគំរាមកំហែង ជាដើម ដោយសារតែមូលហេតុថា គណបក្សនោះមានការព្រួយបារម្ភ ឬការមើលឃើញពីការកើនឡើង នូវប្រជាប្រិយភាពរបស់គណបក្សម្ខាងទៀតនៅពេលបោះឆ្នោតខាងមុខ ទើបបានជាខិតខំព្យាយាមអូសទាញយ៉ាងនេះ។

ប៉ុន្តែការចាកចេញពីគណបក្សដើមរបស់ខ្លួនដែលភាគច្រើនទៅចូលរួមជាមួយគណបក្សប្រជាជនកម្ពុជាដែលជាគណបក្សកាន់អំណាចនោះ គឺមានការបកស្រាយផ្សេងៗ ទៅតាមទស្សនៈនយោបាយ ឬការដោះសាររៀងៗខ្លួន។ តែជារួមគឺពួកគេបានអះអាងស្រដៀងគ្នាថា "ដោយសារបក្សចាស់មិនល្អ ហើយខ្លួនគ្មានឱកាសបានចូលរួមចំណែកអភិវឌ្ឍប្រទេសជាតិ"។ អ្នកដែលចាកចេញជាទូទៅច្រើនតែលើកឡើងថាខ្លួនអស់ជំនឿ អស់សង្ឃឹម និងលើកឡើង ពីចំណុចខ្សោយរបស់ គណបក្ស ដូចជាការប្រកាន់បក្សពួក គ្រួសារនិយម អំពើពុករលួយជាដើម។ អ្នកវិភាគក៏នៅមានការសង្ស័យលើប្រសិទ្ធភាព និងយុទ្ធសាស្ត្រ ដឹកនាំរបស់ប្រធាន និងថ្នាក់ដឹកនាំគណបក្សបន្ទាប់ៗទៀតផងដែរ។



តាមការសង្កេតរយៈពេលចុង ក្រោយនេះតាមអ្វីដែលមន្ត្រីជាន់ខ្ពស់គណបក្សបានកំណត់ថាជា កំណែទំរង់ផ្ទៃក្នុងបក្សនោះ គឺមន្ត្រីជាន់ខ្ពស់របស់ គណបក្ស សម រង្ស៊ីត្រូវបានផ្លាស់ប្តូរមណ្ឌលទៅកាន់ខេត្តផ្សេងៗ ហើយមានតួនាទីទាបជាង មុនផង ពោលគឺអ្នកធ្លាប់ជាប្រធានគណៈកម្មការបក្សខេត្ត ពេលប្តូរទៅកាន់ខេត្តផ្សេងៗនោះបានតួនាទីត្រឹមអនុប្រធានប៉ុណ្ណោះ។ កត្តានេះក៏ ត្រូវមតិខ្លះលើកឡើងថាជាមូលហេតុ ជំរុញឱ្យមានការចាកចេញពីបក្សដែរ ព្រោះថាកាលណា មានតួនាទីជាប្រធានគណៈកម្មការបក្សខេត្ត នោះគេមានអត្ថិភាពឈរឈ្មោះ ក្នុងបញ្ជីបេក្ខជនតំណាងរាស្ត្រលេខរៀង លើគេ ពោលគឺមាន លទ្ធភាពអាចជាប់ជាតំណាងរាស្ត្រនៅពេលដែលគណបក្ស នោះទទួលបានអាសនៈក្នុងមណ្ឌលដែលពួកគេឈរឈ្មោះ។ ម្យ៉ាងទៀតទោះបីមិនមានការបញ្ជាក់ថា ការផ្លាស់ប្តូរនេះ ជាមូលហេតុនៃការចាកចេញ តែវាក៏អាចជា ហេតុផលមួយដែរ ព្រោះការផ្លាស់ប្តូរនេះជាការបង្ហាញពីកត្តាជាច្រើនទៀតដែលជាបញ្ហាផ្ទៃក្នុងរបស់គណបក្ស។

គណបក្សសម រង្ស៊ី ដែលមន្ត្រីរបស់ខ្លួនបានចាកចេញជាបន្តបន្ទាប់នោះ នៅតែអះអាងពីភាពរឹងមាំរបស់ខ្លួន ហើយរឹតរឹងទុកថាការ ចាកចេញរបស់មន្ត្រីគណបក្សមិនមានផលប៉ះពាល់ធ្ងន់ធ្ងរដល់ស្ថានភាពទូទៅរបស់គណបក្ស សម រង្ស៊ីទេ។ គណបក្ស

សមរង្ស៊ីបានចោទប្រកាន់អ្នកចាកចេញទាំងនោះថា បានលក់ឧត្តមគតិរបស់ពួកគេ និងការសំរេចចិត្តរបស់ ពួកគេគឺ ផ្តោតទៅលើមហិច្ឆតា និងប្រយោជន៍ផ្ទាល់ខ្លួន។ ម្យ៉ាងទៀតការចាកចេញរបស់ពួកគេក្នុងពេលនេះ គឺដើម្បីលើកកំពស់ តម្លៃពួកគេឱ្យមានកិរិតជាអតិបរិមា។

ផ្ទុយទៅវិញស្របពេលជាមួយ គ្នានេះគណបក្សប្រជាជនកម្ពុជាឆ្លៀតយកឱកាសនេះដើម្បីធ្វើឱ្យគណបក្ស សមរង្ស៊ីទន់ខ្សោយ។ មិនតែប៉ុណ្ណោះ ថ្នាក់ដឹកនាំជាន់ខ្ពស់ខាងគណបក្សប្រជាជនកម្ពុជាដែលទទួលបានអ្នកចូលថ្មីច្រើន នោះ គឺបានប្រកាសជាសាធារណៈថា នឹងបន្តធ្វើការតែងតាំងមុខ តំណែងជាទីប្រឹក្សាដល់មន្ត្រីជាន់ខ្ពស់នៃគណបក្ស នយោបាយនានាដែលមកចូលរួមជាមួយគណបក្សប្រជាជនកម្ពុជា។ មានការកត់សំគាល់ផងដែរថា មន្ត្រីគណបក្សសម រង្ស៊ី ដែល ត្រូវបានទទួលការតែងតាំងមុខតំណែងជាទីប្រឹក្សាគឺជា មន្ត្រីជាន់ខ្ពស់ក្នុងគណបក្ស និងអ្នកដែលមានមុខ តំណែងប៉ុណ្ណោះ ចំពោះមន្ត្រីថ្នាក់ក្រោមមិនទាន់ឃើញមានការតែងតាំង ឬផ្តល់មុខតំណែងអ្វីទេ។ ចំណែកឯមន្ត្រីជាន់ ខ្ពស់ពីគណបក្សហ្វ៊ុនស៊ិនប៉ិចមួយចំនួនក៏បានធ្វើការចាកចេញពី គណបក្ស ខ្លួនចូលរួមជាមួយគណបក្សប្រជាជនកម្ពុជា ដែរ ទោះបីថាជាគណបក្សសម្ព័ន្ធភាពនឹងគ្នាក៏ដោយ។ តែការចាកចេញពីគណបក្សហ្វ៊ុនស៊ិនប៉ិចនេះ គឺត្រូវបានក្រុមអ្នកតាមដានលើកឡើងនូវមូលហេតុផ្សេងពីគណបក្សសមរង្ស៊ី គឺថាអ្នកខ្លះចូលរួមជាមួយគណបក្ស ប្រជាជនកម្ពុជាដោយសារចង់រក្សាមុខតំណែងដែលខ្លួនមានសព្វថ្ងៃ តែក៏មានអ្នកខ្លះអស់ជំនឿទៅលើភាពខ្លាំងរបស់គណបក្សខ្លួន ក្នុងការប្រកួតប្រជែងជាមួយគណបក្សដៃគូ និងគណបក្សផ្សេងៗទៀត។

ជុំវិញការចាកចេញរបស់អ្នកនយោបាយពីគណបក្សមួយទៅគណបក្សមួយទៀតនេះ មានមតិអ្នកវិភាគលើកឡើងពីស្ថានភាពខុសគ្នារវាងគណបក្សសមរង្ស៊ី និងគណបក្សហ្វ៊ុនស៊ិនប៉ិចដោយផ្អែកលើ**ទឡ្ហីករណ៍**មួយចំនួនដូចជា ចាប់ពីការបោះឆ្នោតឆ្នាំ១៩៩៣ គណបក្សហ្វ៊ុនស៊ិនប៉ិចមានលក្ខណៈធ្ងន់ក្បាល ដោយសារកង្វះខាតការខិតខំពង្រឹង កំលាំង ថ្នាក់មូលដ្ឋាន ដូចនេះ ការចាកចេញរបស់មន្ត្រីជាន់ខ្ពស់គណបក្សមានផលប៉ះពាល់យ៉ាងខ្លាំងដល់គណបក្សនេះ ហើយនេះ ក៏ជាមូលហេតុដែលធ្វើឱ្យគណបក្សមានការធ្លាក់ចុះការគាំទ្រពីអាណត្តិមួយទៅអាណត្តិមួយរហូត។ តែផ្ទុយពីនេះ គណបក្ស សម រង្ស៊ី ក្រៅពីពឹងផ្អែកទៅលើប្រជាប្រិយភាពរបស់ប្រធានបក្ស គណបក្សនេះក៏បានខិតខំធ្វើការយ៉ាងសកម្មក្នុងការពង្រឹងការគាំទ្រនៅតាមមូលដ្ឋាន។ ដូច្នេះ ការចាកចេញរបស់មន្ត្រីជាន់ខ្ពស់ពីគណបក្សសម រង្ស៊ី ប្រហែលជាមិនអាចធ្វើឱ្យគណបក្សនេះមានបញ្ហាធ្ងន់ធ្ងរប៉ុន្មានឡើយ។ ប៉ុន្តែ ផលប៉ះពាល់ពីការចាកចេញនៃសមាជិកទាំងនោះ គឺអាស្រ័យទៅលើឥទ្ធិពលរបស់ពួកគេក្នុងនាមជាកំលាំងស្នូល ក្នុងគណបក្ស និងជាអ្នកធ្វើឱ្យគណបក្សរឹងមាំ ឬរង្គោះរង្គើបាន។ ក្នុងករណីដែលក្រុមអ្នកដែលចាកចេញទាំងនោះមានទំនាក់ទំនងរឹងមាំ និងមានប្រជាប្រិយភាពខ្លាំងជាមួយ អ្នកគាំទ្រនៅ តាមមូលដ្ឋាន ការចាកចេញរបស់ពួកគេនឹងប្រាកដជាមានឥទ្ធិពលអវិជ្ជមានដល់គណបក្សសមរង្ស៊ី។ មិនតែប៉ុណ្ណោះ ការចោទប្រកាន់របស់អ្នកចាកចេញ ទៅលើអំពើពុករលួយ បក្សពួកនិយម អត្តនោម័តនិយមនៅក្នុងគណបក្ស នឹងប៉ះពាល់ដល់កេរ្តិ៍ឈ្មោះរបស់គណបក្សសម រង្ស៊ី ដែលជា គណបក្សមួយដែលបានពង្រឹងកិត្តិនាមរបស់ខ្លួនតាមរយៈគុណធម៌ លទ្ធិប្រជាធិបតេយ្យ និងតម្លាភាព។ ហេតុនេះនៅក្នុងសភាពបែបនេះ ការអះអាងរបស់អ្នកចាកចេញ ប្រហែលជាអាចជំរុញឱ្យអ្នកគាំទ្រគណបក្សនេះមួយចំនួនចាប់ផ្តើមពិចារណាឡើងវិញនូវការជឿជាក់ និងការគាំទ្ររបស់ពួកគេ ទៅលើគណបក្សសមរង្ស៊ី។

ការផ្តល់មុខតំណែងដល់អ្នកចុះចូលជាមួយគណបក្សប្រជាជនកម្ពុជា ត្រូវបាននេះទទួលការ រិះគន់ពីសំណាក់ មន្ត្រីគណបក្សប្រឆាំង និងមន្ត្រីអង្គការសង្គមស៊ីវិលផងដែរថា ជាការមិនស្របនិងច្បាប់ ហើយក៏បានចំណាយថវិកា ជាតិច្រើនហួសហេតុ ទៅលើបៀវត្សទីប្រឹក្សា នាយករដ្ឋមន្ត្រីក៏ដូច ទីប្រឹក្សារាជរដ្ឋាភិបាល និងជាការទិញ ឬទាក់ទាញទឹកចិត្ត សមាជិកគណបក្សនយោបាយផ្សេងៗឱ្យចូលគណបក្សកាន់អំណាច។ ទន្ទឹមនឹងការផ្តល់មុខតំណែងដល់ សមាជិកគណបក្ស នយោបាយដទៃនោះ គណបក្សប្រជាជនកម្ពុជាក៏បាន និងកំពុងធ្វើការតែងតាំងអភិបាលអភិបាលរងខេត្ត ក្រុង ជាទីប្រឹក្សាមានឋានៈស្មើរដ្ឋមន្ត្រី ឬរដ្ឋលេខាធិការផងដែរ។

បើពិនិត្យជាគោលការណ៍ មុខតំណែងទីប្រឹក្សាដែលមានឋានៈស្មើរដ្ឋមន្ត្រី ឬរដ្ឋលេខាធិការ (ជាសមាជិករដ្ឋាភិបាល) គួរតែទទួល ការឯកភាពពីរដ្ឋសភាមុននឹងធ្វើការតែងតាំង។ ហើយអ្នកដែលសមស្របបំផុតសំរាប់តំណែង ទីប្រឹក្សាគឺគួរតែជាអ្នកចូលនិវត្តន៍ ដោយហេតុថា បើអ្នកត្រូវបានតែងតាំងជាទីប្រឹក្សាជាអ្នកមានតួនាទីក្នុងរាជរដ្ឋាភិបាល ស្ថាប័នជាតិ ឬក្នុងមុខងារសាធារណៈ នោះអាចនាំឱ្យមានទំនាស់ផលប្រយោជន៍។ ម្យ៉ាងទៀត ស្ថានភាពបច្ចុប្បន្ននៃរាជរដ្ឋាភិបាលកម្ពុជា គឺមានទីប្រឹក្សាច្រើនលើសលប់ពេក ដោយអ្នកទាំងនោះរួមមានមន្ត្រីរាជការ អ្នកនយោបាយ អ្នកជំនួញ និងថ្មីៗនេះ មានទាំងសមាជិកគណបក្សនយោបាយនានាដែលចុះចូលជាមួយគណបក្សប្រជាជនកម្ពុជា។

**អ្នកឃ្លាំមើល**

# សង្ខេបលទ្ធផលការងារសំខាន់ៗរបស់ខុមហ្វ្រែល ឆ្នាំ២០០៧

គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា ខុមហ្វ្រែល បានខិតខំប្រឹងប្រែងយ៉ាងខ្លាំងដើម្បីបំពេញសកម្មភាពតាមកម្មវិធីដូចខាងក្រោម ក្នុងរយៈពេលពីខែ កញ្ញា ឆ្នាំ ២០០៦ ដល់ខែតុលា ឆ្នាំ ២០០៧ ហើយសម្រេចបានលទ្ធផលគួរឱ្យកត់សម្គាល់។ ខុមហ្វ្រែលបានចូលរួមជាមួយនឹងស្ថាប័នផ្សេងៗទៀត យ៉ាងសកម្ម ក្នុងការធ្វើឱ្យប្រសើរឡើងនូវក្របខណ្ឌ និងស្ថាប័នគតិយុត្តិ ដោយជួយឱ្យការអនុវត្តលិខិតគតិយុត្តិ ទាំងនោះកាន់តែបើកទូលាយ មានតម្លាភាព និងកាន់តែទទួលបានច្រើន ថែមទាំងបង្កើនការយល់ដឹង ចំណេះដឹង និងផ្លាស់ប្តូរឥរិយាបថរបស់ក្រុមគោលដៅ។



*កិច្ចប្រជុំ NGOs និងគណបក្សដើម្បីផ្តល់អនុសាសន៍ដល់ គ.ជ.ប*

អនុសាសន៍ និងការឆ្លើយតបខាងក្រោមនេះ ពាក់ព័ន្ធជាមួយនឹងបញ្ហាសំខាន់ៗ ដែលកើតឡើងនៅអំឡុងពេលមុនការបោះឆ្នោត។ អង្គការខុមហ្វ្រែលបានធ្វើយុទ្ធនាការ និងការតស៊ូមតិតាមរយៈកិច្ចពិភាក្សា និងការប្រជុំ ជាមួយស្ថាប័នពាក់ព័ន្ធនឹងការបោះឆ្នោត ទាក់ទងនឹងបញ្ហាចម្បងៗកើតឡើងនៅក្នុងការបោះឆ្នោតឆ្នាំ ២០០៧ ហើយនិងការព្រួយបារម្ភចំពោះការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រដែលនឹងចូលមកដល់នាពេលខាងមុខនេះ។ យ៉ាងហោចណាស់មានអនុសាសន៍សំខាន់ៗចំនួន ៥០% ត្រូវបានទទួលយក យោងតាមការឆ្លើយតបរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) នៅថ្ងៃទី ៣០ ខែ កញ្ញា ឆ្នាំ ២០០៦ និងអ្វីដែលមានចែងនៅក្នុងសេចក្តីណែនាំ និងវិធាននៃការបោះឆ្នោត។

គ.ជ.ប បានទទួលយកអនុសាសន៍របស់ខុមហ្វ្រែល ទៅលើការរៀបចំការទទួលបានប្រព័ន្ធផ្សព្វផ្សាយដោយ ស្មើភាព ដោយបានព្យាយាមធ្វើឱ្យមានការទទួលបានប្រព័ន្ធផ្សព្វផ្សាយស្មើគ្នានៅក្នុងការឃោសនាបោះឆ្នោតឆ្នាំ ២០០២។ នៅក្នុងយុទ្ធនាការឃោសនាបោះឆ្នោតឆ្នាំ ២០០៧ គ.ជ.ប បានអនុវត្តកម្មវិធីសមធម៌ ដែលអនុញ្ញាតឱ្យ គណបក្សនយោបាយទាំងអស់បោះផ្សាយគោលនយោបាយរបស់ពួកគេ។ លើសពីនេះទៀត កម្មវិធីព័ត៌មានសមធម៌ នៅតាមកញ្ចក់ទូរទស្សន៍ ត្រូវបានបង្កើតឡើងរួមគ្នាដោយកម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិ (UNDP) និង ទូរទស្សន៍ជាតិកម្ពុជា (ទ.ទ.ក-TVK) ដោយផ្អែកលើគោលការណ៍សមធម៌ក្នុងការផ្តល់ពេលវេលាឱ្យគណបក្ស នយោបាយទាំងអស់។ កម្មវិធីនេះ ធ្វើការផ្សព្វផ្សាយជាសំខាន់ទៅលើព្រឹត្តការណ៍នៃការបោះឆ្នោតជ្រើសរើសក្រុម ប្រឹក្សាឃុំ-សង្កាត់ និងការឃោសនាបោះឆ្នោតរបស់គណបក្សនយោបាយ។ កម្មវិធីទាំងពីរត្រូវបានចាក់ផ្សាយ តាមរយៈប្រព័ន្ធផ្សព្វផ្សាយអេឡិចត្រូនិចរបស់រដ្ឋ ពោលគឺ ទ.ទ.ក វិទ្យុ FM៩៦ MHz និង AM៩១៨ KHz ពីថ្ងៃទី ១៦ ដល់ ៣០ ខែមីនា ឆ្នាំ ២០០៧។ កម្មវិធីបោះឆ្នោតរបស់គ.ជ.បរួមមានទាំងភាសាប្រើសញ្ញាសម្រាប់មនុស្សគ-ថ្លង់ផងដែរ។ មានការប្រសើរឡើងជាបន្តួរនៅក្នុងការទទួលបានប្រព័ន្ធផ្សព្វផ្សាយនេះ ជាពិសេសចំពោះគណបក្ស ជំទាស់សំខាន់ (គណបក្សសម រង្ស៊ី) គណបក្សដៃគូនៅក្នុងរដ្ឋាភិបាលចំរុះ (គណបក្សហ្វ៊ុន ស៊ិនប៉ិច) និងចំពោះ គណបក្សតូចៗ នៅក្នុងកម្រិតប្រែប្រួលមិនច្បាស់លាស់មួយ។ ទោះបីជាយ៉ាងណាក៏ដោយ គណបក្សប្រជាជនកម្ពុជា បន្តទទួលបានគុណសម្បត្តិយ៉ាងខ្លាំង នៅក្នុងការផលិតចេញពីប្រព័ន្ធផ្សព្វផ្សាយពាក់ព័ន្ធនឹងការបោះឆ្នោតជាផ្លូវការ និងបណ្តាញគ្របដណ្តប់ព័ត៌មានជាទូទៅ។

មានការរៀបចំរចនាសម្ព័ន្ធគ.ជ.ប ឡើងវិញ។ ការផ្លាស់ប្តូរនេះផ្អែកលើការបែងចែកអាសនៈ ពាក់ព័ន្ធនឹង អាសនៈគណបក្សនយោបាយនៅក្នុងរដ្ឋសភា ជាឧទាហរណ៍គឺជាការតំណាងច្បាស់លាស់ជាងមុន នូវការផ្សារភ្ជាប់ នឹងនយោបាយ ហើយមានការបែងចែករវាងសមាជិកសំឡេងប្រឆាំង ឬសមាជិកមិនមែនមកពីគណបក្សប្រជាជនកម្ពុជា។ ការផ្លាស់ប្តូរនេះ គួរតែចូលរួមចំណែកឱ្យមានតម្លាភាពថែមទៀតនៅក្នុងការបំពេញការងារ (ការផ្លាស់ប្តូរ របស់គ.ជ.ប ក្នុងការអនុវត្តការងារ)។ ទោះជាយ៉ាងណាក៏ដោយ សង្គមស៊ីវិលមើលឃើញថា ប្រព័ន្ធថ្មីនេះបោះបង់ ចោលនូវគោលដៅរបស់គ.ជ.ប ក្នុងនាមជាស្ថាប័នរដ្ឋឯករាជ្យ អព្យាក្រឹត្យត្រឹមត្រូវ ហើយលក្ខណៈវិនិច្ឆ័យទាំងឡាយសំដៅបង្ការសមាជិករបស់ខ្លួនពីភាពលម្អៀងផ្អែកនយោបាយ មិនទាន់ត្រូវបានកំណត់ ក៏ដូចជានីតិវិធីជ្រើស រើសសមាជិក

គ.ជ.ប មិនទាន់មានលក្ខណៈត្រឹមត្រូវនៅឡើយ។ ជាការពិត ដំណើរការជ្រើសរើសនេះត្រូវបានធ្វើ ឡើងដោយក្រសួងមហាផ្ទៃ ដែលស្ថិតនៅក្រោមការត្រួតពិនិត្យដោយគណបក្សប្រជាជនកម្ពុជា នៅក្នុងរដ្ឋាភិបាលចំរុះ។ តំណាងអង្គការខុមហ្វ្រែល ក្រុមការងារ និងគណៈកម្មាធិការជំនាញរបស់ខ្លួន មានសេចក្តីសប្បាយរីករាយ ដែលបានជួបប្រាស្រ័យជាមួយមេដឹកនាំគណបក្សនយោបាយសំខាន់ពីរ នៅក្នុងការបោះឆ្នោតក្រុមប្រឹក្សាឃុំ-សង្កាត់ និងជាមួយឯកឧត្តមសខេងឧបនាយករដ្ឋមន្ត្រីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រួមជាមួយនឹងអ្នកតាក់តែងច្បាប់ និងមន្ត្រី របស់គ.ជ.ប។ គោលបំណងនៃជំនួបនោះគឺដើម្បីបញ្ចុះបញ្ចូលឱ្យមានកំណែទម្រង់ការបោះឆ្នោត ជាពិសេសទៅលើ ការកែប្រែរចនាសម្ព័ន្ធរបស់គ.ជ.ប ក៏ដូចជានីតិវិធីសម្រាប់ការបោះឆ្នោតនៅឆ្នាំ ២០០៧។ ចំនួនសមាជិកគ.ជ.ប ដែលអញ្ជើញមកពីគណបក្សនយោបាយជាប់ឆ្នោតនៅក្នុងរដ្ឋសភា បានកើនឡើងពីចំនួន ៥ រូប ទៅចំនួន ៩ រូប (៥រូបពីគណបក្សប្រជាជនកម្ពុជា ២រូបមកពីគណបក្សសម រង្ស៊ី និង២ រូបទៀតមកពីគណបក្សហ៊្វុន សិុនប៉ិុច)។

នៅអំឡុងការចុះឈ្មោះបោះឆ្នោតនៅឆ្នាំ ២០០៧ គ.ជ.ប បានបង្កើតសេចក្តីណែនាំ និងដំណើរការមួយ ដើម្បីសម្អាតបញ្ជីឈ្មោះអ្នកបោះឆ្នោត សម្រាប់ការបោះឆ្នោតតំណាងរាស្ត្រខាងមុខនេះ។ គ.ជ.ប[១] បានពន្យល់ថា បញ្ហានេះគឺដើម្បីឆ្លើយតបតាមអនុសាសន៍របស់អង្គការខុមហ្វ្រែល ដែលបានលើកឡើងបន្ទាប់ពីការធ្វើសវនកម្មលើ បញ្ជីឈ្មោះអ្នកបោះឆ្នោត នៅឆ្នាំ ២០០៥ និងដែលបានរកឃើញថា ១០%នៃអ្នកបោះឆ្នោត គឺជាអ្នកបោះឆ្នោតខ្មោច(អ្នកបោះឆ្នោតខ្មោច មានន័យថា ជាអ្នកដែលមិនមានរូបរាង ឬមិនត្រូវបានដឹង ឬស្គាល់ដោយអ្នកភូមិ ឬអាជ្ញាធរដែនដី) ហើយ២០%នៃទិន្នន័យនោះមានលក្ខណៈមិនត្រឹមត្រូវ។

អ្នកបោះឆ្នោតទទួលបានការយល់ដឹង និងចំណេះដឹងច្រើនឡើងពាក់ព័ន្ធនឹងដំណើរការបោះឆ្នោត និងសារៈសំខាន់នៃការបោះឆ្នោត។ មានការថយចុះនូវចំនួនសន្លឹកឆ្នោតមិនបានការបើប្រៀបធៀបនឹងការបោះឆ្នោតកន្លងមក។ អ្នកបោះឆ្នោតមានការតាំងកើនឡើងដើម្បីនឹងទៅបោះឆ្នោត ដោយខុមហ្វ្រែលបានកត់សម្គាល់ឃើញមាន ការកើនឡើងនូវការចូលរួមរបស់ប្រជាពលរដ្ឋនៅក្នុងការបោះឆ្នោត។ ចំនួនសន្លឹកឆ្នោតសរុបនៅក្នុងការបោះឆ្នោត ក្រុមប្រឹក្សាឃុំ-សង្កាត់ឆ្នាំ ២០០៧ មានចំនួន ៥,១៧ លាននាក់ ពោលគឺខ្ពស់ជាងការបោះឆ្នោតពីមុនៗមក ដូចជា នៅក្នុងការបោះឆ្នោតឃុំ-សង្កាត់ឆ្នាំ ២០០២ មានចំនួនតែ ៤,៣៤ លាននាក់។ ទោះបីជាយ៉ាងណាក៏ដោយ ចំនួនអ្នកចេញទៅបោះឆ្នោត បានថយចុះជាភាគរយ ហើយអ្នកបោះឆ្នោតជួបប្រទះនឹងឧបសគ្គ និងនីតិវិធីស្មុគស្មាញ នៅ អំឡុងពេលចុះឈ្មោះបោះឆ្នោត និងបោះឆ្នោត។



*កិច្ចប្រជុំវាយតំលៃលើការងាររបស់ខុមហ្វ្រែល*

អង្គការខុមហ្វ្រែលកត់សម្គាល់ឃើញថា មានការផ្លាស់ប្តូរផ្នែកឥរិយាបថមួយចំនួន ក្នុងចំណោមមន្ត្រីគ.ជ.ប មន្ត្រីរៀបចំការបោះឆ្នោតនៅតាមខេត្ត/ក្រុង និងឃុំ-សង្កាត់។ លទ្ធផលនេះពាក់ព័ន្ធនឹងការឆ្លើយតបប្រកបដោយ ថាមពលឱ្យមានជាសកម្មភាព ដែលលើកឡើងដោយអង្គការខុមហ្វ្រែល អង្គការសង្កេតការណ៍បោះឆ្នោតផ្សេងទៀត និងគណបក្សនយោបាយ ទោះបីជាសកម្មភាពទាំងអស់មិនសុទ្ធតែវិជ្ជមានក៏ដោយ។ លើសពីនេះទៀត សហប្រតិបត្តិការរវាងគ.ជ.ប និងសង្គមស៊ីវិល និងរវាងគ.ជ.ប និងគណបក្សនយោបាយ មានភាពប្រសើរជាង នៅក្នុងការបោះឆ្នោតមុនៗ ក្នុងការរៀបចំកិច្ចប្រជុំជាទៀងទាត់ ដើម្បីដោះស្រាយ និងបង្ការបញ្ហាទំនាស់បោះឆ្នោត ធានាឱ្យទទួលបានការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយរដ្ឋស្មើគ្នា ផលិតសេចក្តីណែនាំអំពីការបោះឆ្នោតសម្រាប់អព្យាក្រឹតភាពរបស់មេភូមិ និងអាជ្ញាធរដែនដី។ល។ វត្តមានរបស់អាជ្ញាធរដែនដីនៅក្បែរស្ថានីយ៍បោះឆ្នោត និងស្ថានីយ៍ រាប់សន្លឹកឆ្នោតក៏មានការថយចុះប្រៀបធៀបនឹងការបោះឆ្នោតមុនៗ ហើយការនេះនាំទៅដល់ការ

១ បញ្ហានេះត្រូវបានថ្លែងឱ្យដឹងពីសំណាក់ប្រធានគ.ជ.ប នៅក្នុងកិច្ចប្រជុំមួយ នៅថ្ងៃទី ២ វិច្ឆិកា ២០០៧។ យ៉ាងហោចណាស់ សមាជិកគ.ជ.ប ចំនួន ២ រូប បានផ្ញើលិខិតអំណរគុណ ដែលជាលទ្ធផលនៃអនុសាសន៍គតិយុត្តិរបស់ខុមហ្វ្រែល ហើយបាន អញ្ជើញនាយកប្រតិបត្តិខុមហ្វ្រែលឱ្យផ្តល់យោបល់។

តទៅទំព័រទី ១៤

អត្ថបទស្រាវជ្រាវ : (តចប់ពីលេខមុន)

# ការរៀបចំបន្លំការបោះឆ្នោត និងវិធីទប់ទល់នឹងបញ្ហានេះ

ដោយលោក Daniel Calingaert
Associate Director of the Center for Democracy and Election Management and professional lecturer at American University
Journal of Democracy Volume 17, Number 3, July 2006
The Johns Hopkins University Press
ប្រែសម្រួលដោយ កំសាន្ត

## ដំណាក់កាលទីបីៈ នៅថ្ងៃបោះឆ្នោត

នៅថ្ងៃបោះឆ្នោត របបផ្តាច់ការតាមការបោះឆ្នោត បានប្រើវិធីផ្សេងគ្នាជាច្រើន ដើម្បីរកសំឡេងឆ្នោតសរុបដល់ បេក្ខជនរបស់ខ្លួន ហើយវិធីទាំងនេះលំបាកនឹងរកឱ្យឃើញ។ ទោះបីជានៅថ្ងៃបោះឆ្នោត ការសង្កេតនៅក្នុងស្រុក និងពីក្រៅស្រុកបានដាក់ការយកចិត្តទុកដាក់យ៉ាងខ្លាំងលើដំណើរការបោះឆ្នោតក៏ដោយ ក៏ការកៃបន្លំជាច្រើនមិនត្រូវបានរកឃើញ ដោយអ្នកសង្កេតការណ៍ឡើយ។ ការកៃបន្លំ និងបោកបញ្ឆោតមិនអាចត្រូវបានរកឃើញឡើយ នៅពេលដែលអ្នកសង្កេតការណ៍មិនត្រូវបានអនុញ្ញាតឱ្យចូលទៅក្នុងស្ថានីយ៍បោះឆ្នោត ឬត្រូវបានរារាំងមិនឱ្យមើលដំណើរការរាប់សន្លឹកឆ្នោត។ ជាក់ស្តែង របបកាន់អំណាចធ្លាប់ត្រូវរកឃើញថា មានទោសពីការកៃបន្លំការបោះឆ្នោតនៅក្នុងការបោះឆ្នោតប្រធានាធិបតីនៅ ប្រទេសអេហ្ស៊ីបនៅឆ្នាំ២០០៥ និងក្នុងការបោះឆ្នោតជាតិនៃប្រទេសនីហ្សេរីយ៉ាឆ្នាំ២០០៣។ នៅប្រទេសអេហ្ស៊ីប បន្ត្រីសន្តិសុខបានប្រព្រឹត្តធ្ងន់ធ្ងរហួតដល់ការបំផ្លាញសន្លឹកឆ្នោតបោះឱ្យបេក្ខជនគណបក្សប្រឆាំង។ នៅប្រទេសនីហ្សេរីយ៉ា ហិបឆ្នោតត្រូវបានដាក់បន្ថែមសន្លឹកឆ្នោតនៅថ្ងៃបោះឆ្នោត នៅចំពោះមុខអ្នកសង្កេតការណ៍បោះឆ្នោតតែម្តង។

ការបោះឆ្នោតច្រើនដងគឺជាវិធីមួយទៀត នៃការកៃបន្លំការបោះឆ្នោត។ ពេលខ្លះ អ្នកបោះឆ្នោតមានឈ្មោះក្នុងបញ្ជី អាចរកបធ្យោបាយបោះឆ្នោតលើសពីមួយសន្លឹក។ នៅពេលខ្លះទៀត បុគ្គលដែលគេមិនស្គាល់ លេចឡើងនៅក្នុងការិយាល័យបោះឆ្នោតដើម្បីបោះឆ្នោតជំនួសឱ្យអ្នកបោះឆ្នោតដែលបានស្លាប់ទៅហើយ។

ការទិញសន្លឹកឆ្នោតគឺជាយុទ្ធវិធីដ៏ស្រួចស្រាវមួយផ្សេងទៀត។ ទោះបីយ៉ាងណាក៏ដោយ ភ្នាក់ងាររបស់រដ្ឋាភិបាលរបបផ្តាច់ការមិន



អាចពឹងផ្អែកតែលើវិធីសំណូកនេះរហូតនោះទេ ពីព្រោះអ្នកបោះឆ្នោតអាចទទួលយកលុយ ឬអំណោយនោះ។ ប៉ុន្តែបោះឆ្នោតឱ្យបេក្ខជនគណបក្សប្រឆាំង។ នៅប្រទេសថៃ នៅពេលគណបក្សកាន់អំណាចចែកចាយអង្ករជា ថ្នូរនឹង សន្លឹកឆ្នោត គណបក្សប្រឆាំងបានប្រាប់ អ្នកបោះឆ្នោតឱ្យយកអង្ករទាំងនោះ ប៉ុន្តែសូបប្រជាពលរដ្ឋធ្វើការបោះឆ្នោតតាមឆន្ទៈ។ ការទិញសន្លឹកឆ្នោតជាធម្មតាមានប្រសិទ្ធភាពតាម ការចង់បានអ្នកធ្វើសំណូកតែនៅពេលដែលភាពសម្ងាត់នៃ សន្លឹកឆ្នោតមិន ត្រូវបានធានា ឬនៅពេលវាប្រព្រឹត្តឡើងជាមួយនឹងការគាបសង្កត់ទៅលើអ្នកទទួលសំណូកនោះ។ ជាក់ស្តែងនៅក្នុងការបោះឆ្នោតប្រធានាធិបតីប្រទេសអេហ្ស៊ីបឆ្នាំ ២០០៥ ភ្នាក់ងាររបស់គណបក្សប្រជាធិបតេយ្យជាតិ (គណបក្សកាន់អំណាច) ត្រូវបានគេរាយការណ៍ថា បានផ្តល់លុយដល់អ្នកបោះឆ្នោត ហើយអបដំណើរអ្នកទាំងនោះ ចូលទៅក្នុងស្ថានីយ៍បោះឆ្នោត ដើម្បីធានាថា ពួកគេបោះឆ្នោតឱ្យប្រធានាធិបតី Hosni Mubarak។ នៅឯប្រទេសសេប៊ីវិញ នៅអំឡុងទសវត្សរ៍ឆ្នាំ៩០ ភ្នាក់ងារ របស់អតីតប្រធានាធិបតី ស្លូបូដាន មីឡូស្វ៊ិច បានប្រឌិតរឿងឡើងផ្សេងៗ ដើម្បីធានាថា អ្នកទទួលសំណូកនឹងបោះឆ្នោតឱ្យលោកមីឡូស្វ៊ិច។ សកម្មជនគណបក្សប្រឆាំងបានរាយការថា ភ្នាក់ងាររបស់លោកមីឡូស្វ៊ិច បានដាក់គោលដៅទៅលើអ្នកបោះឆ្នោតជាក្រុម ដូចជាកម្មករ កម្មការិនីពីរោងចក្ររបស់រដ្ឋ ជាដើម។ អ្នកបោះឆ្នោតទីមួយត្រូវបានផ្តល់សន្លឹកឆ្នោតដែលគូសឱ្យលោកមីឡូសេវ៉ិចរួចជាមុនស្រេច ហើយបន្ទាប់ បកត្រូវបានណែនាំឱ្យចូលក្នុងបន្ទប់បោះឆ្នោតដើម្បីទម្លាក់សន្លឹកឆ្នោតនោះ។ អ្នកបោះឆ្នោតរូបនោះនឹងចេញពីស្ថានីយ៍បោះឆ្នោត ហើយផ្តល់សន្លឹកឆ្នោតមិនទាន់គូសទៅឱ្យភ្នាក់ងារគណបក្ស

ដើម្បីទទួលបានលុយ។ ជាបន្ត ភ្នាក់ងារនោះគូស សន្លឹកឆ្នោតឱ្យលោក ប៊ីឡូសេរ៉ិច ហើយផ្តល់សន្លឹកឆ្នោតនេះទៅអ្នកបោះឆ្នោតទី២ នៅក្នុងក្រុមនោះ ដែលអ្នកទី២នេះ ក៏ត្រូវបានបង្គាប់ឱ្យធ្វើដូចគ្នានឹងអ្នកបោះឆ្នោតទីមួយ។ តាមរយៈវិធីនេះ ភ្នាក់ងារគណបក្សធានាថា អ្នកបោះឆ្នោតនៅក្នុង ក្រុមបោះឆ្នោតនោះ បានបោះឆ្នោតឱ្យលោក ប៊ីឡូសេរ៉ិច ហើយវិធីនេះពិបាកនឹងចាប់បានណាស់ លើកលែងតែមានអ្នកបោះឆ្នោតណាម្នាក់ក្នុងចំណោមនោះរាយការណ៍ពីអំពើនេះ។

ភ្នាក់ងាររបស់គណបក្សកាន់អំណាចអាចប្រើប្រាស់បច្ចេកទេសដាក់តាំងសម្ភារៈឃោសនាការរបស់ខ្លួននៅក្នុងបន្ទប់ បោះឆ្នោត ហើយមន្ត្រីរៀបចំការបោះឆ្នោតអាចពន្យល់នីតិវិធីបោះឆ្នោត តាមរបៀបដែលផ្តល់ផលចំណេញដល់បេក្ខជន គណបក្សកាន់អំណាច។ បុគ្គលដែលមិនមានភារកិច្ចនៅក្នុងបន្ទប់បោះឆ្នោត ជារឿយៗគឺមន្ត្រីសន្តិសុខ អាចរំខានដោយផ្ទាល់ ឬដោយប្រយោលដល់ដំណើរការបោះឆ្នោត ហើយសន្លឹកឆ្នោតដែលគូសហើយអាចត្រូវទម្លាក់ដោយមិនបត់ ដើម្បីអាចមើលឃើញបានដោយមន្ត្រីរៀបចំការបោះឆ្នោត ឬភ្នាក់ងារគណបក្សនយោបាយ។

ភាពប្រថុយនឹងការបន្លំសន្លឹកឆ្នោតកាន់តែធំទៅទៀត នៅពេលអ្នកបោះឆ្នោត បោះឆ្នោតនៅក្រៅស្ថានីយ៍ ដោយសារតែសន្លឹកឆ្នោតទាំងនេះងាយស្រួលនឹងបន្លំ។ នៅក្នុងប្រទេសជាច្រើន ប្រអប់ឆ្នោតចល័តត្រូវបានបញ្ជូនទៅផ្ទះ អ្នកបោះឆ្នោត ដែលឈឺ ចាស់ជរា ឬមិនអាចធ្វើដំណើរទៅស្ថានីយ៍បោះឆ្នោតបាន ហើយដូច្នេះមន្ត្រីរៀបចំការបោះឆ្នោត អាចបង្ខំអ្នកបោះឆ្នោតទាំងនេះបោះឆ្នោតឱ្យគណបក្សកាន់អំណាច។ ប្រសិនបើប្រអប់ឆ្នោតទាំងនោះ មិនត្រូវបានអមដំណើរដោយភ្នាក់ងារគណបក្សប្រឆាំងទេនោះ នោះវានឹងជាគោលដៅងាយស្រួលចំពោះភ្នាក់ងារគណបក្សកាន់អំណាច ដែលស្វែងរកឱកាសទម្លាក់សន្លឹកឆ្នោតដោយខុសច្បាប់ទៅក្នុងប្រអប់ឆ្នោត។ នៅប្រទេសអ៊ុយក្រែន មានករណីមួយ ចំនួន ដែលសន្លឹកឆ្នោតបានមកពីការបោះឆ្នោតចល័តមានចំនួន៣០% ហើយនៅក្នុងករណីទាំងនោះហត្ថលេខារបស់អ្នកបោះឆ្នោតចល័តមើលទៅមានលក្ខណៈស្រដៀងគ្នា ដែលធ្វើឱ្យអ្នកសង្កេតការណ៍មានការសង្ស័យ។

**ដំណាក់កាលទីបួនៈ ការរាប់ និងគណនាសន្លឹកឆ្នោត**

បន្ទាប់ពីស្ថានីយ៍បោះឆ្នោតបានបិទ ការរាប់សន្លឹកឆ្នោតអាចផ្តល់នូវឱកាសថែមទៀតដល់ភ្នាក់ងាររបស់គណបក្សកាន់អំណាចដើម្បីលួចសន្លឹកឆ្នោត។ មន្ត្រីការិយាល័យបោះឆ្នោតទំនងជាអាចផ្តល់ការពេញចិត្តដល់គណបក្សកាន់អំណាច ដោយការបកស្រាយតាមចំណង់ទៅលើបញ្ញត្តិស្តីពីសុពលភាពនៃសន្លឹកឆ្នោត។ ពោលគឺ នៅពេលសន្លឹកឆ្នោត ណាមួយត្រូវបានគូសមិនត្រឹមត្រូវ ប៉ុន្តែបំណងនៃការគូសរបស់អ្នកបោះឆ្នោតគឺច្បាស់លាស់ហើយនោះ ពួកគេអាចសម្រេចថាគ្មានសុពលភាពបើគំនូសធ្វើសម្រាប់គណបក្សប្រឆាំងប៉ុន្តែ សម្រេចថាមានសុពលភាពបើការគូសនោះធ្វើឱ្យគណបក្សកាន់អំណាច។ នៅបណ្តាប្រទេសដែលនីតិវិធីបោះឆ្នោតកំណត់ថា សន្លឹកឆ្នោត គ្មានសុពលភាពបើសិនមានគំនូសខុសទីតាំងបន្តិចបន្តួច មន្ត្រីការិយាល័យបោះឆ្នោតអាចគូស-បន្ថែមលើសន្លឹកឆ្នោតដែលបោះឱ្យ គណបក្សប្រឆាំង។ នៅពេលមន្ត្រីទាំងនោះបំពេញរបាយការណ៍រាប់សន្លឹកឆ្នោតរបស់ការិយាល័យបោះឆ្នោត ពួកគេអាចបំប៉ោងតួលេខ លទ្ធផលឱ្យគណបក្សកាន់អំណាច ឬកាត់បន្ថយសំឡេងពីគណបក្សប្រឆាំង។ មន្ត្រីដែលជាប់ពាក់ព័ន្ធនឹងគណបក្សកាន់អំណាចទំនងជា អុកឡុកលទ្ធផលនៅការិយាល័យបោះឆ្នោត ដែលគ្មានវត្តមានគណបក្សប្រឆាំង ឬអ្នកសង្កេតការណ៍ឯករាជ្យ។



ការគណនាសំឡេងឆ្នោត ក៏អាចត្រូវបានបន្លំតាមបច្ចេកទេសជាច្រើន។ វិធីមួយគឺ គណបក្សកាន់អំណាច អាចអុកឡុកនឹងប្រអប់ឆ្នោត នៅពេលដឹកជញ្ជូនពីការិយាល័យបោះឆ្នោត ទៅមណ្ឌលរាប់សន្លឹកឆ្នោតនៅខេត្ត-ក្រុង។ នៅក្នុងការបោះឆ្នោតតំណាងរាស្ត្រឆ្នាំ ២០០៥ នៅប្រទេសអេត្យ៉ូពី ហិបឆ្នោតមួយចំនួនត្រូវបានលួច អំឡុងពេលដឹកជញ្ជូន ហើយត្រូវបំផ្លាញចោល ដោយឃើញនៅមានកំទេចកំទីរាយប៉ាយនៅតាមផ្លូវ។ មន្ត្រីនៅមណ្ឌលរាប់សន្លឹកឆ្នោត អាចក្លែងខុសរបាយការណ៍ផ្លូវការ នៅពេលពួកគេប្រមូលផ្តុំសរុបលទ្ធផលបោះឆ្នោតពីការិយាល័យបោះឆ្នោត។

*តទៅលេខក្រោយ*

# ការវាយតម្លៃរបស់យុវជនអំពីការបំពេញរបស់រាជរដ្ឋាភិបាលកម្ពុជា ឬ គណបក្សនយោបាយជាប់ឆ្នោតនៅលើការបណ្តុះបណ្តាល និងការបង្កើតការងារ នៅក្នុងមណ្ឌលខេត្តកំពង់ចាម និងខេត្តកណ្តាល

**ការវាយតម្លៃរបស់ម្ចាស់**ឆ្នោតជាយុវជនចំនួនប្រមាណ **១២៦** នាក់ នៅខេត្តកំពង់ចាម(១៩ កុម្ភៈ ២០០៨) និង**៧០** នាក់ នៅខេត្តកណ្តាល(១២ មីនា ២០០៨) ដែលបានចូលរួមក្នុងវេទិកាដែលរៀបចំឡើង ដោយ **ខុមហ្វ្រែល** សហការ ជាមួយ **ក្រុមប្រឹក្សាយុវជនកម្ពុជា សមាគម យុវជនខ្មែរ និងកម្មវិធីអភិវឌ្ឍន៍ធនធានយុវជន** និងបន្ទាប់ពីមានការពិភាក្សា និងស្តាប់នូវរបាយការណ៍ ជាក់ស្តែងខ្លះរបស់ វាគ្មិន ទាក់ទិននឹងការអនុវត្តវិស័យបណ្តុះបណ្តាលនិងការបង្កើតការងារ។ ការវាយតម្លៃបានផ្តោតទៅលើ ៥ចំណុចចម្បង។ ដូចជា (១)-ការអនុវត្តគោលនយោបាយសំដៅបង្កើតការងារ របស់រាជរដ្ឋាភិបាល (២)-ការពង្រឹងនូវការអនុវត្ត ច្បាប់ការងារ និងអនុសញ្ញាអន្តរជាតិនានាដើម្បីធានានូវសិទ្ធិ និងផលប្រយោជន៍របស់កម្មករ និយោជិត និងនិយោជក (៣)-ការ បង្កើតបណ្តាញបណ្តុះបណ្តាលជំនាញ វិជ្ជាជីវៈផ្សារភ្ជាប់នឹងមជ្ឈមណ្ឌលសម្រាប់ជួយរកការងារធ្វើឱ្យយុវជន (៤)-ការបង្កើត មជ្ឈមណ្ឌលបណ្តុះបណ្តាល និងផ្សព្វផ្សាយពលរដ្ឋវិជ្ជាដល់យុវជន និងការបង្កើតបណ្ណាល័យសាធារណៈ និង(៥)-ការពង្រឹង ការគ្រប់គ្រងពលករបរទេសនៅកម្ពុជាក្នុងទិសដៅដោះស្រាយការងារធ្វើ និងស្រូបយកបច្ចេកវិទ្យាថ្មី។ អ្នកចូលរួមក្នុងវេទិកាត្រូវដាក់ពិន្ទុទៅ លើចំណុចទាំងនេះ **ចន្លោះពី ១: មិនពេញចិត្តសោះ** ទៅ **៥: ពេញចិត្តខ្លាំងណាស់**។

វាគ្មិនកិត្តិយសដែលបានអញ្ជើញចូលរួមៈ

**ខេត្តកំពង់ចាមៈ**

ចំនួន ៤ រូបរួមមានអ្នកតំណាងរាស្ត្រក្នុងមណ្ឌលកំពង់ចាម ឯកឧត្តម **ម៉ោញ សាផាន** និងឯកឧត្តម **ម៉ៅ មុនីវណ្ណ** ប្រធានសមាគមអាជីវកម្មប្រចាំខេត្តកំពង់ចាមលោក **នាង សុវ៉ាត** និងប្រធានមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តកំពង់ចាម លោក **ចេង ប៊ាង** ទាក់ទិននឹងការអនុវត្តវិស័យបណ្តុះបណ្តាល និងការបង្កើតការងារ។



**ខេត្តកណ្តាលៈ**

ចំនួន ៤ រូប រួមមាន អ្នកតំណាងរាស្ត្រក្នុងមណ្ឌលកណ្តាល ឯកឧត្តម **ខៀវ សន** និងឯកឧត្តម **ចាន់ ចេង** តំណាងក្រុមប្រឹក្សាយុវជនកម្ពុជាប្រចាំខេត្តកណ្តាល លោក **ផេង សៅឆេង** និងអនុប្រធានមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តកណ្តាល លោក **គឹម សារ៉ា**។

**លទ្ធផលវាយតម្លៃ មានដូចខាងក្រោមៈ**

**ខេត្តកំពង់ចាម**

១- ចំពោះ**ការអនុវត្តគោលនយោបាយសំដៅបង្កើតការងាររបស់រាជរដ្ឋាភិបាល** អ្នកចូលរួមវេទិកាជាយុវជនបានឱ្យ ពិន្ទុ **២,៥៤**។ ពិន្ទុនេះសំដៅទៅកំរិត**ពេញចិត្តត្រឹមតិចតួចបំផុត**។ ក្នុងនោះ អ្នកផ្តល់ពិន្ទុ **១** (មិនពេញចិត្តសោះ) មាន **៤%** អ្នកផ្តល់ពិន្ទុ **២** (ពេញចិត្តតិចតួចបំផុត) មាន **៤៣%** អ្នកផ្តល់ពិន្ទុ **៣** (ពេញចិត្តគួរសម) មាន **៤៩%** អ្នកផ្តល់ពិន្ទុ **៤** (ពេញចិត្តច្រើន) មាន**៣%** និងអ្នក ផ្តល់ពិន្ទុ **៥** (ពេញចិត្តខ្លាំងណាស់) មានតែ **១%** ប៉ុណ្ណោះ។ ការពិភាក្សាបានរកឃើញថា កំណើនទីផ្សារការងារនៅក្នុងមណ្ឌល មិនសមាមាត្រទៅនឹងកំណើនយុវជនដែលនាំឱ្យមានចំណាកស្រុករបស់យុវជនដើម្បីរកការងារធ្វើ។ អង្គវេទិកាក៏បានលើកឡើងផងដែរថា យុវជនមួយចំនួនមិនបានសិក្សាជំនាញ ឱ្យចំនឹងទីផ្សារការងារ ហើយការអប់រំមិនមានគុណភាពដែលធ្វើឱ្យយុវជនមិនមានសមត្ថភាពគ្រប់គ្រាន់ក្នុងការបំពេញការងារ។ អ្នកតំណាងរាស្ត្រ **ម៉ោញ សាផាន** បានមានប្រសាសន៍ថា ការបណ្តុះបណ្តាលនៅក្នុងខេត្ត កំពង់ចាម គឺមិនសូវត្រូវនឹងទីផ្សារការងារក្នុងខេត្តនេះ។ ឧទាហរណ៍ ខេត្តកំពង់ចាម គឺជាខេត្តដំណាំឧស្សាហកម្ម កៅស៊ូ ក៏ប៉ុន្តែមិនមានការបណ្តុះបណ្តាលជំនាញទាក់ទងនឹងការងារខាងកៅស៊ូទេ។ ទោះបីយ៉ាងណាប្រធានមន្ទីរ ការងារនឹងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តកំពង់

ចាម លោក **ចេង ហ៊ាង** បានឱ្យដឹងថា នៅខេត្តកំពង់ចាម មានកំណើន ទីផ្សារការងារដោយក្នុងឆ្នាំ ២០០៧ នេះ មានគ្រឹះស្ថានចំនួន ២៧៣ ដែលមានកម្មករ/បុគ្គលិកចំនួន ២១.០០០ នាក់ បើប្រៀបធៀបទៅនឹងឆ្នាំ ២០០៦ មាន គ្រឹះស្ថានប្រមាណ ១៦០ និង កម្មករ/បុគ្គលិកចំនួន ១៦.០០០ នាក់។

២- ចំណែកឯ**ការពង្រឹងនូវការអនុវត្តច្បាប់ការងារនិងអនុសញ្ញាអន្តរជាតិនានាដើម្បីធានានូវសិទ្ធិ និងផលប្រយោជន៍ របស់កម្មករ និយោជិត និងនិយោជក** អ្នកចូលរួមវេទិកាជាយុវជនបានឱ្យពិន្ទុ **២,៤៧**។ ពិន្ទុនេះសំដៅទៅកំរិត **ពេញចិត្តត្រឹមតិចតួចបំផុត**។ ក្នុងនោះអ្នកផ្តល់ពិន្ទុ ១ (មិនពេញចិត្តសោះ) មាន **៥%** អ្នកផ្តល់ពិន្ទុ **២** (ពេញចិត្តតិចតួចបំផុត) មាន **៥៣%** អ្នកផ្តល់ពិន្ទុ **៣** (ពេញចិត្តគួរសម) មាន **៣៣%** អ្នកផ្តល់ពិន្ទុ **៤** (ពេញចិត្តច្រើន) មាន **៨%** និងអ្នកផ្តល់ពិន្ទុ **៥** (ពេញចិត្តខ្លាំងណាស់) មាន **១%**។

ការពិភាក្សាបានរកឃើញថា ការអនុវត្តច្បាប់នៅទន់ខ្សោយ ហើយនៅមានអំពើពុករលួយដូចជាការសូកលុយដើម្បី អាចចូលបម្រើការងារនៅរោងចក្រ ឬស្ថាប័នគ្រឹះស្ថានមួយចំនួន។ អ្នកតំណាងរាស្ត្រ **ម៉ៅ មុនីវណ្ណ** បានលើកឡើងថា បុគ្គលិក ចំការកៅស៊ូខ្លះ ត្រូវបានគេបាញ់សម្លាប់ ហើយឃាតកមិនដែលត្រូវបានចាប់បានឡើយ។ លោក **ចេង ហ៊ាង** ទទួលស្គាល់ ថាក្នុងឆ្នាំ២០០៧ មានទំនាស់ការងារចំនួន ៦ករណី ក៏ប៉ុន្តែទំនាស់ទាំងនេះត្រូវបានផ្សះផ្សារជាទាំងអស់។

៣- ចំពោះ**ការបង្កើតបណ្តាញបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈផ្សារភ្ជាប់នឹងមជ្ឈមណ្ឌលសម្រាប់ជួយរកការងារធ្វើឱ្យយុវជន** អ្នកចូលរួមវេទិកាជាយុវជនបានឱ្យពិន្ទុ **២,៤៨**។ ពិន្ទុនេះសំដៅទៅកំរិត**ពេញចិត្តត្រឹមតិចតួចបំផុត**។ ក្នុងនោះ អ្នកផ្តល់ពិន្ទុ **១** (មិនពេញចិត្តសោះ) មាន **១%** អ្នកផ្តល់ពិន្ទុ **២** (ពេញចិត្តតិចតួចបំផុត) មាន **៥៩%** អ្នកផ្តល់ពិន្ទុ **៣** (ពេញចិត្តគួរសម) មាន **៣៤%** អ្នកផ្តល់ពិន្ទុ **៤** (ពេញចិត្តច្រើន) មាន **៤%** និងអ្នកផ្តល់ពិន្ទុ **៥** (ពេញចិត្តខ្លាំងណាស់) មាន **២%**។ ការពិភាក្សា បានរកឃើញថា នៅខេត្តកំពង់ចាមមានមជ្ឈមណ្ឌលបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈតាំងពីឆ្នាំ ១៩៩៤។ ក៏ប៉ុន្តែនៅខេត្តកំពង់ចាម មិនទាន់មានការិយាល័យផ្តល់ព័ត៌មានពីការងារនៅឡើយទេ។ ការពិភាក្សា បានរកឃើញថាយុវជនភាគច្រើនមិនចាប់អារម្មណ៍ នឹងមុខជំនាញនៅមជ្ឈមណ្ឌលទេ ហើយអ្នកតំណាងរាស្ត្រ **ម៉ោញ សាផាន** បាន លើកឡើងថា ការបណ្តុះបណ្តាលនៅទីនោះ មិនសូវត្រូវនឹងតម្រូវការទីផ្សារការងារ។

៤- បីទោះជាចំណុចទី៤ (**ការបង្កើតមជ្ឈមណ្ឌលបណ្តុះបណ្តាល និងផ្សព្វផ្សាយពលរដ្ឋវិជ្ជាដល់យុវជន និងការបង្កើតបណ្ណាល័យសាធារណៈបន្ថែមទៀត**) មិនសូវមានព័ត៌មានបានបង្ហាញក៏ដោយ ក៏អ្នកចូលរួមវេទិកាជាយុវជន បានឱ្យពិន្ទុ **២,៣៣**។ ពិន្ទុនេះសំដៅទៅកំរិត**ពេញចិត្តត្រឹម តិចតួចបំផុត**។ ក្នុងនោះអ្នកផ្តល់ពិន្ទុ **១** (មិនពេញចិត្តសោះ) មាន **១៥%** អ្នកផ្តល់ពិន្ទុ **២** (ពេញចិត្តតិចតួចបំផុត) មាន **៤៨%** អ្នកផ្តល់ពិន្ទុ **៣** (ពេញចិត្តគួរសម) មាន **២៩%** អ្នកផ្តល់ពិន្ទុ **៤** (ពេញចិត្តច្រើន) មាន **៥%** និងអ្នកផ្តល់ពិន្ទុ **៥** (ពេញចិត្តខ្លាំងណាស់) មាន **៣%**។

៥- **ការពង្រឹងការគ្រប់គ្រងពលករបរទេសនៅកម្ពុជា ក្នុងទិសដៅដោះស្រាយការងារធ្វើ និងស្រូបយកបច្ចេកវិទ្យាថ្មី** អ្នកចូលរួមវេទិកាជាយុវជនបានឱ្យពិន្ទុ **២,៣២**។ ពិន្ទុនេះសំដៅទៅកំរិត**ពេញចិត្តត្រឹមតិចតួចបំផុត**។ ក្នុងនោះ អ្នកផ្តល់ពិន្ទុ **១** (មិនពេញចិត្តសោះ) មាន **១២%** អ្នកផ្តល់ពិន្ទុ **២** (ពេញចិត្តតិចតួចបំផុត) មាន **៥០%** អ្នកផ្តល់ ពិន្ទុ **៣** (ពេញចិត្តគួរសម) មាន **៣២%** អ្នកផ្តល់ពិន្ទុ **៤** (ពេញចិត្តច្រើន) មាន **៥%** និងអ្នកផ្តល់ពិន្ទុ **៥** (ពេញ ចិត្តខ្លាំងណាស់) មានតែ **១%** ប៉ុណ្ណោះ។

អង្គវេទិកាបានលើកឡើងថា រាជរដ្ឋាភិបាលអាចមានលទ្ធភាពគ្រប់គ្រងពលករបរទេសស្របច្បាប់ ក៏ប៉ុន្តែមានពលករបរទេស ខុសច្បាប់ជាច្រើនដែលបានមកដណ្តើមការងារពលរដ្ឋខ្មែរ។ លោក **ចេង ហ៊ាង** បានឱ្យដឹងថា នៅខេត្ត កំពង់ចាមមានពលករ បរទេសតែ **៧០** នាក់ប៉ុណ្ណោះ ខណៈដែលពលករខ្មែរមានដល់ទៅ **២១.០០០** នាក់ ក្នុងគ្រឹះស្ថានទាំង ២៧៣។ លោកបាន ឱ្យដឹងទៀតថា មន្ទីរបានត្រួតពិនិត្យពលករបរទេសទាំងនេះជារៀងរាល់ឆ្នាំ។ ក៏ប៉ុន្តែ អ្នកចូលរួម និងវាគ្មិនដទៃទៀតបានលើកឡើងថា មានពលករបរទេសខុសច្បាប់ជាច្រើនបានមកចូលបម្រើការនៅខេត្តកំពង់ចាម ដូចជានៅចម្ការកៅស៊ូ ដែលរដ្ឋាភិបាលមិនអាចគ្រប់គ្រងបាន។

**ជាសរុប ពិន្ទុជាមធ្យមនៃការបំពេញរបស់រដ្ឋាភិបាល ឬ**

*តទៅទំព័រទី ១៦*

# ឃ្លាំមើលសភា និង តំណាងរាស្ត្រសំរាប់ខែធ្នូ ២០០៧-កុម្ភៈ ២០០៨

ក្នុងរយៈពេល ៣ ខែ (ធ្នូ ២០០៧ ដល់ កុម្ភៈ ២០០៨) រដ្ឋសភាបានបើកសម័យប្រជុំពេញអង្គរបស់ខ្លួនសរុបចំនួន ១៧ព្រឹក ដោយបានពិភាក្សា និង អនុម័តនូវសេចក្តីព្រាងច្បាប់ សេចក្តីស្នើច្បាប់ និងកិច្ចព្រមព្រៀងមួយចំនួន។ ជាមួយគ្នានេះដែរ រដ្ឋសភា ក៏បានធ្វើ ការប្រកាសសុពលភាពអ្នកតំណាងរាស្ត្រថ្មី និងបានបោះឆ្នោតតែងតាំងសមាជិកគណៈកម្មការជំនាញនៃរដ្ឋសភាផងដែរ។ ក្នុងត្រីមាស នេះដែរ ខុមហ្វ្រែលទទួលបានព័ត៌មានថា មាន**អ្នកតំណាងរាស្ត្រយ៉ាងតិចចំនួន ៤ រូប ដែលក្នុងនោះ ៣ រូប មកពីគណបក្សសមរង្ស៊ី និង ១ រូប មកពីគណបក្សហ្វ៊ុនស៊ិនប៉ិច បានដាក់លិខិតយ៉ាងតិចចំនួន ១៥** ទៅកាន់ស្ថាប័នរាជរដ្ឋាភិបាល ដោយរួមទាំងការ**អញ្ជើញមន្ត្រីរាជរដ្ឋាភិបាលមកបំភ្លឺ ក្នុងនៅសម័យប្រជុំសភាពេញអង្គ**ផងដែរ ។

## ចុះទៅកាន់មណ្ឌលនានារបស់អ្នកតំណាងរាស្ត្រ



តាមព័ត៌មានដែលខុមហ្វ្រែលបានទទួលបាន មានអ្នកតំណាងរាស្ត្រយ៉ាងតិចចំនួន **៦៩ រូប** បានចុះមូលដ្ឋានយ៉ាងតិចចំនួន **៤៣៧ លើក**។ ក្នុងចំណោមតំណាងរាស្ត្រទាំង **៦៩ រូប** មានតំណាងរាស្ត្រគណបក្ស **ប្រជាជនកម្ពុជា** ចំនួន **៤១ រូប** (ស្មើនឹង **៥៦%** នៃចំនួន តំណាងរាស្ត្ររបស់គណបក្សនេះសរុប) បានធ្វើសកម្មភាពចុះមូលដ្ឋានច្រើនជាងគេ រហូតដល់ **២៧០ លើក** (ស្មើនឹង **៦២%** នៃការចុះមូលដ្ឋានសរុបរបស់អ្នកតំណាងរាស្ត្រទាំងអស់) ដោយមានការតាមពីក្រោយដោយអ្នកតំណាងរាស្ត្រមកពីគណបក្ស **សមរង្ស៊ី** សរុបចំនួន **១៧ រូប** (ស្មើនឹង **៧១%** នៃចំនួនតំណាងរាស្ត្ររបស់គណបក្ស នេះសរុប) បានធ្វើសកម្មភាពចុះមូលដ្ឋានយ៉ាងតិចចំនួន **១១៧ លើក** (ស្មើនឹង ២៧ %)។

ដោយឡែក អ្នកតំណាងរាស្ត្រមកពីគណបក្ស **ហ្វ៊ុនស៊ិនប៉ិច** សរុបចំនួន **១១ រូប** (ស្មើនឹង **៤២%** នៃចំនួនតំណាងរាស្ត្ររបស់គណបក្សនេះសរុប) បានចុះធ្វើសកម្មភាពបានតែ **៥០ លើក** (ស្មើនឹង១១%) ប៉ុណ្ណោះ។គោលបំណងនៃការចុះមូលដ្ឋានទាំងនេះគឺដើម្បីសួរសុខទុក្ខធ្វើអន្តរាគមន៍ជួយដោះស្រាយបញ្ហារបស់ប្រជាពលរដ្ឋ សម្ពោធសមិទ្ធផលនានា ចែកអំណោយ ពង្រឹង បណ្តាញផ្ទៃក្នុង និងជួបសកម្មជនគណបក្ស ឬដើម្បីចូលរួមក្នុងវេទិកាសាធារណៈរបស់អង្គការមិនមែនរដ្ឋាភិបាល ក៏ដូចជាការអមដំណើរជាក្រុម/ថ្នាក់ដឹកនាំគណបក្សខ្លួន ។

ក្នុងចំណោមអ្នកតំណាងរាស្ត្រដែលបានចុះមូលដ្ឋានទាំង **៤១ រូប** របស់គណបក្ស **ប្រជាជនកម្ពុជា** អ្នកតំណាងរាស្ត្រមណ្ឌលបាត់ដំបង **ទេស ហ៊ាញ** បាននាំមុខគេក្នុងការចុះពង្រឹង បណ្តាញគណបក្ស និងសួរសុខទុក្ខប្រជាពលរដ្ឋក្នុងមណ្ឌលរបស់ខ្លួន ដោយបានធ្វើការចុះមូលដ្ឋាន សរុបចំនួន **២៥ លើក** និងស្ថិតក្នុង លំដាប់ថ្នាក់ទី **១** ក្នុងចំណោមតំណាងរាស្ត្រចុះមូលដ្ឋានទាំង **៦៩ រូប** ក្នុងត្រីមាសនេះ ។ ជាឧទាហរណ៍ កាលពីថ្ងៃទី ១៩ មករា ឆ្នាំ ២០០៨ ឯកឧត្តម **ទេស ហ៊ាញ** បានអញ្ជើញជួបប្រាស្រ័យការងារជាមួយក្រុមប្រឹក្សាឃុំទាំងអស់ក្នុងស្រុកបាណន់ នៅសាលាស្រុកបាណន់ ខេត្តបាត់ដំបង ។ រីឯក្នុងចំណោងអ្នកតំណាងរាស្ត្រមកពីគណបក្ស **សមរង្ស៊ី** ដែលចុះមូលដ្ឋានទាំង **១៧ រូប** អតីតតំណាងរាស្រមណ្ឌលកំពង់ធំ **សុក ផេង** បាននាំមុខគេក្នុងចុះសួរសុខទុក្ខ និងជួយអន្តរាគមន៏ដោះស្រាយបញ្ហារបស់ប្រជាពលរដ្ឋក្នុង និងក្រៅមណ្ឌលរបស់ខ្លួនផងដែរ ដោយបានចុះ មូលដ្ឋានចំនួន **២៤ លើក** ហើយស្ថិតក្នុងលំដាប់ថ្នាក់ទី **២** ដូចជាក្នុងករណីដែលឯកឧត្តម **សុក ផេង** បានចុះជួបប្រជាពលរដ្ឋមកពីតំបន់ដីក្រហម ក្នុងសង្កាត់ទន្លេបាសាក់ ខ័ណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី ២៣ មករា ដើម្បីជួយធ្វើអន្តរាគមន៏ដោះស្រាយបញ្ហាដីធ្លីជូនពួកគាត់ ព្រមទាំងបាន ជួយទំនាក់ទំនងជាមួយអង្គការនានាអោយជួយឃ្លាំមើលករណីដីធ្លីនេះផងដែរ ខណៈដែលអ្នកតំណាងរាស្ត្រមណ្ឌលកណ្តាល **ខៀវ សន** មកពីគណបក្ស **ហ្វ៊ុនស៊ិនប៉ិច** បាននាំមុខគេក្នុងការអញ្ជើញចូលរួមជាវាគ្មិនក្នុងវេទិការសាធារណៈស្តីពីទំនាក់ទំនងរវាងតំណាងរាស្ត្រ និងម្ចាស់ឆ្នោត ក្នុងចំណោមអ្នក តំណាងរាស្ត្រមកពីគណបក្សរបស់ខ្លួនដែលបានចុះមូលដ្ឋានទាំង **១១ រូប** ហើយឯកឧត្តម **ខៀវ សន** ស្ថិតក្នុងចំណាត់ថ្នាក់ទី **៦** ក្នុងចំណោមអ្នកតំណាង រាស្ត្រដែលបានចុះមូលដ្ឋាន ទាំង **៦៩ រូប** ។ ឧទាហរណ៍កាលពីថ្ងៃទី ១៩ ធ្នូ ឯកឧត្តម **ខៀវ សន** បានអញ្ជើញចូលរួមជាវាគ្មិនក្នុងវេទិកាសធារណៈស្តីពី តំណាងរាស្ត្រ និងម្ចាស់ឆ្នោតក្នុងស្រុកកោះធំ ខេត្តកណ្តាល ។

**តារាងទី១:** ចំនួនលើកនៃការចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រតាមគោលបំណងផ្សេងៗដែលខុមហ្វ្រែលទទួលបាន

| គោលបំណងចុះមូលដ្ឋាន សរុប ៤៣៧លើក នៃអ្នកតំណាងរាស្ត្រសរុប ៦៩ រូប | គណបក្សនយោបាយ | | | សរុបគោលបំណង |
|---|---|---|---|---|
| | ២៩ រូប | ១០ រូប | ៦ រូប | |
| សាកសួរសុខទុក្ខ ចែកអំណោយនិង ការសម្ពោធសមិទ្ធផលនានា | ១០៣ | ៦៤ | ៣០ | ១៩៧ (៤៤%) |
| ការចុះពង្រឹងផ្ទៃក្នុង និង បណ្តាញគណបក្ស | ១១៦ | ២៣ | ៣ | ១៤២ (៣៣%) |
| ការចុះអមដំណើរជាក្រុម ឬអមដំណើរថ្នាក់ដឹកនាំ | ៣៨ | 0 | 0 | ៣៨ (៩%) |
| ការចូលរួមក្នុងវេទិកាសាធារណៈ | ១២ | ១៦ | ១៦ | ៤៤ (១០%) |
| ការអន្តរាគមន៍ និងដោះស្រាយបញ្ហានានា | ១ | ១៤ | ១ | ១៦ (៤%) |
| **សរុបតាមគណបក្ស** | ២៧០ | ១១៧ | ៥០ | ៤៣៧ (១០០%) |

**តារាងទី១ បានបង្ហាញថា:** ក្នុងត្រីមាសនេះ អ្នកតំណាងរាស្ត្រមកពីគណបក្សទាំងបីមានសកម្មភាពខ្លាំងក្នុងការចុះសួរសុខទុក្ខ ចែកអំណោយ និងសម្ពោធសមិទ្ធផលនានា ដែលសរុបមានចំនួន **១៩៧ លើក** (ស្មើនឹង **៤៤%** នៃគោលបំណងចុះមូលដ្ឋានសរុប) ដោយតាមពីក្រោយ ដោយការចុះមូលដ្ឋានដើម្បីពង្រឹងផ្ទៃក្នុង និងបណ្តាញរបស់គណបក្សខ្លួនតាមមណ្ឌលនានាទូទាំងប្រទេសសរុបចំនួន **១៤២ លើក** (ស្មើនឹង **៣៣%** នៃគោលបំណងចុះ មូលដ្ឋានសរុប) ខណៈដែលអ្នកតំណាងរាស្ត្រទាំង **៦៩ រូប** បានយកចិត្តទុកដាក់តិចតួចលើការអមតំណើរថ្នាក់ដឹកនាំ ដោយមានចំនួនសរុបតែ **៣៨ លើក** (ស្មើនឹង **៩%**) ការចូលរួមវេទិកាសាធារណៈ **៤៤ លើក** (ស្មើនឹង **១០%**) និងការអន្តរាគមន៍ ក៏ដូចជាការដោះស្រាយបញ្ហានានារបស់ប្រជា ពលរដ្ឋតាមមណ្ឌលរបស់ខ្លួននៅគ្រប់ខេត្តក្រុងទាំងអស់មានត្រឹមតែ **១៦** លើក (ស្មើនឹង **៤%**) ប៉ុណ្ណោះ ។

## សង្ខេបព្រឹត្តិការណ៍សំខាន់ៗទាក់ទិនសភា និង តំណាងរាស្ត្រ

### <u>ការផ្លាស់ប្តូរសមាជិកសភាថ្មី</u>

សមាជិកសភាចំនួន ៧ រូប ត្រូវបានធ្វើការផ្លាស់ប្តូរនៅក្នុងខែកុម្ភៈនេះ ដែល ៦ រូបក្រោមហេតុផលប្រាសចាកសមាជិកភាពពីគណបក្សរបស់ខ្លួន និង ១ រូបទៀតបានទទួលមរណភាព ។ ចលនានៃការផ្លាស់ប្តូរនេះបានធ្វើឡើងខណៈពេលដែលចលនាការផ្លាស់ប្តូរគណបក្សនយោបាយ ដោយអ្នកតំណាង រាស្ត្រចេះតែកើនឡើង និងការអូសទាញពីគណបក្សកាន់អំណាចតាមរយៈការផ្តល់តំណែងក្នុងជួររាជរដ្ឋាភិបាល នៅពេលដែលការបោះឆ្នោតជ្រើស តាំងតំណាងរាស្ត្រកាន់តែខិតជិតមកដល់ ។ តំណាងរាស្ត្រគណបក្សសមរង្ស៊ីចំនួន ៤ រូប បានចាកចេញពីគណបក្សដែលក្នុងនោះ ៣ រូប បានចូលរួមជា មួយគណបក្ស**ប្រជាជនកម្ពុជា** និង ១ រូបទៀតជាមួយគណបក្ស **ហ្វ៊ុនស៊ិនប៉ិច** ។ ចំណែកតំណាងរាស្ត្រគណបក្ស **ហ្វ៊ុនស៊ិនប៉ិច** ២ រូប បានចាកចេញ ពីបក្សទៅចូលរួមជាមួយគណបក្ស **ប្រជាជនកម្ពុជា** ផងដែរ ។ ទោះបីជាគណបក្សនយោបាយនីមួយៗបាននិយាយថា ការចាកចេញនេះមិនបានប៉ះពាល់ដល់គណបក្ស និងជាសិទ្ធិនយោបាយបុគ្គលក្តី តែវាបានជះឥទ្ធិពលដល់ការសម្រេចចិត្តរបស់ប្រជាពលរដ្ឋ និងធ្វើអោយប្រជាពលរដ្ឋវង្វេង តាមមិនទាន់ ។ ជាមួយគ្នានេះការអនុវត្តមាត្រា ១២០នៃច្បាប់ស្តីពីការជ្រើសតាំងតំណាងរាស្ត្រដែលចែងថា សមាជិកសភាត្រូវបាត់បង់សមាជិកភាព របស់ខ្លួននៅពេលប្រាសចាកពីសមាជិកគណបក្សរបស់ខ្លួន ត្រូវបានសង្គមស៊ីវិល និងតំណាងរាស្ត្រមួយចំនួនយល់ថាជាការរឹតបន្តឹងសិទ្ធិអំណាច និងឯករាជ្យភាពរបស់តំណាងរាស្ត្រ ។ តំណាងរាស្ត្រទាំង ៧ រូប ដែលត្រូវផ្លាស់ប្តូររួមមាន: អ្នកតំណាងរាស្ត្រគណបក្ស **ហ្វ៊ុនស៊ិនប៉ិច** ឯកឧត្តម **សូរ វិចទ័រ** តំណាងរាស្ត្រមណ្ឌលស្វាយរៀង ត្រូវជំនួសដោយ ឯកឧត្តម **ប៉ុល ម៉ែងហួរ** ។ ឯកឧត្តម **ឃិន យាន** តំណាងរាស្ត្រមណ្ឌលសៀមរាបដែលបានទទួល មរណភាព ត្រូវជំនួសដោយឯកឧត្តម **ប៊ិន ហេងប៉ូល** ។ ឯកឧត្តម **ស៊ិន ពិនសេន** តំណាងរាស្ត្រមណ្ឌលព្រៃវែង ត្រូវជំនួសដោយឯកឧត្តម **គជ ច័ន្ទថា** ។ ចំណែកឯអ្នកតំណាងរាស្ត្រគណបក្ស **សមរង្ស៊ី** ឯកឧត្តម **សុក ផេង** តំណាងរាស្ត្រមណ្ឌល កំពង់ធំ ត្រូវជំនួសដោយឯកឧត្តម **កែត ឃី** ។ ឯកឧត្តម **គៀង វ៉ាង** តំណាងរាស្ត្រមណ្ឌលកំពត ត្រូវជំនួសដោយឯកឧត្តម **វ៉ាន់ ដាវ៉ា** ។ ឯកឧត្តម **អះម៉ាត់ យ៉ះយ៉ា** តំណាងរាស្ត្រមណ្ឌលកំពង់ចាម ត្រូវជំនួសដោយឯកឧត្តម **នួន វុទ្ធី** និងឯកឧត្តម **ង៉ោ សុវណ្ណ** តំណាងរាស្ត្រមណ្ឌលកណ្តាល ត្រូវជំនួសដោយលោកជំទាវ **ពត ពៅ** ។

*តទៅទំព័រទី ១៨*

តមកពីទំព័រទី២

# ការអង្កេតរបស់ខុមហ្វ្រែលលើការវិវត្តបរិយាកាសនយោបាយ...

(ទទក) ឃើញថា គណបក្ស **ប្រជាជន កម្ពុជា** ត្រូវបាន ផ្សព្វផ្សាយ ឮ និងបង្ហាញក្នុង **ទទក ៨៤%** (ស្មើនឹង **១៣៥លើក**) នៃការលើកឡើង ឬផ្សព្វផ្សាយពី គណបក្សនយោបាយទាំងអស់នៅ ក្នុង **ទទក**។ មានតែគណបក្ស **ប្រជាជនកម្ពុជា** តែមួយ ប៉ុណ្ណោះ ដែលសមិទ្ធផល ក៏ដូចជាជោគជ័យ នានារបស់គណបក្សខ្លួនត្រូវបាន ផ្សព្វផ្សាយដោយ **ទទក**។ គណបក្ស **ហ្វ៊ុនស៊ិនប៉ិច** ត្រូវបានផ្សព្វផ្សាយ ឮ និង បង្ហាញតែ**១៣%** (ស្មើនឹង **២១លើក**)ឯគណបក្ស **សមរង្ស៊ី** ដែលជាគណបក្ស នៅក្រៅរដ្ឋាភិបាលត្រូវបានឮឈ្មោះតែ**៥ដង**ប៉ុណ្ណោះ។ ដើម្បីពង្រឹងការគោរព ច្បាប់បោះឆ្នោត គោលការណ៍ណែនាំរបស់ គ.ជ.ប និងក្រមសីលធម៌ប្រព័ន្ធផ្សព្វផ្សាយវិទ្យុ និងទូរទស្សន៍ឯកជនមួយចំនួន ស្ថិតក្រោមឥទ្ធិពលគណបក្សកាន់អំណាចត្រូវតែបើកចំហ និងផ្តល់លទ្ធភាពឱ្យគណបក្សផ្សេងអាចប្រើប្រាស់ និងមានព័ត៌មានមតិរបស់ពួកគេនៅក្នុងការផ្សាយនានា។



**ខុមហ្វ្រែល នៅតែមានការព្រួយបារម្ភចំពោះគុណភាពនៃបញ្ជី ដែលបានធ្វើឱ្យបាត់សិទ្ធិអ្នកបោះឆ្នោត** មួយ ចំនួនដែលឈ្មោះ របស់ពួកគេត្រូវបាន **លុបដោយមិនត្រឹមត្រូវ និងការផ្លាស់ប្តូរព័ត៌មានស្តីពីទីតាំងការិយាល័យ**។ បញ្ជីឈ្មោះអ្នកបោះឆ្នោតផ្លូវការ សម្រាប់បម្រើការបោះឆ្នោតឆ្នាំ ២០០៨ បានបង្ហាញថា មានអ្នកបោះឆ្នោត ៨.១២៤.០៩២ ដែលអាច មានការផ្លាស់ប្តូរការិយាល័យ របស់អ្នកបោះឆ្នោតច្រើន ព្រោះថា គ.ជ.ប បានប្រើប្រាស់ប្រព័ន្ធរៀបចំបញ្ជី ឈ្មោះអ្នកបោះ ឆ្នោតតាមអក្ខរក្រម ស្របពេលនោះ គ.ជ.ប បានលុបឈ្មោះអ្នកបោះឆ្នោត រហូតដល់ជិត ៦០ ម៉ឺននាក់។ ការចុះឈ្មោះថ្មី បានរហូតដល់ ៩១១.៨៨១ នាក់ ដែលលើសការប៉ាន់ស្មាន របស់ គ.ជ.ប ប្រមាណជិត ២៣ ម៉ឺននាក់ (គ.ជ.ប ប៉ាន់ស្មានថា ក្នុងឆ្នាំ ២០០៧ នឹងមានអ្នកចុះឈ្មោះ ប្រមាណ ៦៨២.៤៥៩ នាក់)។ ទាំងការចុះឈ្មោះបោះឆ្នោត និងការលុបឈ្មោះអ្នក បោះឆ្នោតត្រូវបានធ្វើប្រតិបត្តិការ និងផ្តល់ព័ត៌មានជាមូលដ្ឋានមកពីមេឃុំ/ចៅសង្កាត់ និងមេភូមិ ឬក្រុម ប្រឹក្សាឃុំ/សង្កាត់ ដែលស្ទើរតែទាំងអស់ គឺជាសមាជិកគណបក្សប្រជាជនកម្ពុជា។

ក្នុងបញ្ហា **គុណភាពបញ្ជីឈ្មោះ** អង្គការសង្គមស៊ីវិលធ្វើការងារពាក់ព័ន្ធនឹងការបោះឆ្នោត[១០] ធ្វើ សវនកម្មលើ បញ្ជី ឈ្មោះអ្នកបោះឆ្នោតផ្លូវការ។ ខុមហ្វ្រែល ក៏មានផែនការនឹងដាក់អ្នកសង្កេតការណ៍រយៈ ពេលខ្លីដើម្បីជួយ អ្នកបោះឆ្នោតនៅក្រៅការិយាល័យបោះឆ្នោតក្នុងការរកឈ្មោះ និងទីតាំងការិយាល័យ។ ជាមួយគ្នានេះ **ខុមហ្វ្រែល** ក៏សូមអបអរសាទរ ចំពោះគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដែលបាន ខិតខំបង្ហោះបញ្ជីឈ្មោះអ្នកបោះឆ្នោត នៅលើគេហទំព័ររបស់ខ្លួន ដើម្បីឱ្យអ្នកបោះឆ្នោតផ្ទៀងផ្ទាត់ទិន្នន័យរបស់ខ្លួន (www.voterlist.org.kh) ប៉ុន្តែគេនៅ លើកជាសំនួរថា តើមានអ្នកបោះឆ្នោត កម្ពុជាប៉ុន្មាននាក់ ដែលអាចប្រើប្រាស់បច្ចេកវិជ្ជាថ្មីនេះ។ ដូចនេះ ខុមហ្វ្រែល ស្នើឱ្យ គ.ជប ត្រូវខិតខំយកចិត្តទុកដាក់ក្នុងការ **បែងចែកប័ណ្ណព័ត៌មានអ្នកបោះឆ្នោត** ដែលធ្វើយ៉ាងដូចម្តេចឱ្យប័ណ្ណទាំងនោះបាន **ដល់ដៃអ្នកបោះឆ្នោតគ្រប់គ្នា**។

ខុមហ្វ្រែល សូមវាយតំលៃខ្ពស់ចំពោះ គ.ជ.ប ដែលបើកទូលាយដល់គណបក្សនយោបាយ និងអង្គការសង្គមស៊ីវិល ក្នុងការផ្តល់អនុសាសន៍លើសេចក្តីព្រាងបទបញ្ជា និងនីតិវិធី ដើម្បីធ្វើឱ្យមានភាព ប្រសើរជាងមុន។ ប៉ុន្តែ នីតិវិធី ក្នុងការទទួលពិចារណាលើអនុសាសន៍ **គឺមានភាពមិនយកចិត្តទុកដាក់លើហេតុផល**។ គ.ជ.ប មិនបានផ្តល់ឱកាស ឱ្យគណបក្ស នយោបាយនិងអង្គការសង្គមស៊ីវិលដែលបានផ្តល់ អនុសាសន៍ធ្វើការពិភាក្សា បកស្រាយឬលើកអំណះ អំណាង បន្ថែមទៅលើ អនុសាសន៍ឡើយ។ ខុមហ្វ្រែល នៅមានការព្រួយបារម្ភ ដែល គ.ជ.ប សម្រេចមិនកែលម្អនីតិវិធី សំខាន់ៗ ដែលទាក់ទងនឹងបញ្ហាដូចខាងក្រោម ដោយគ្រាន់តែមានលិខិតឆ្លើយតប ហើយមិនមានការពន្យល់មូលហេតុច្បាស់លាស់។ បញ្ហាសំខាន់ៗ ខាងក្រោម ដែល គ.ជ.ប មិនទាន់ចែងឱ្យច្បាស់នៅក្នុងបទបញ្ជា និងនីតិវិធី ដែលអាចបង្កឱ្យការអនុវត្តជួប ទំនាស់ និងភាពមិនប្រក្រតីកើតឡើងដដែលដូចជា:

- **ការទិញសន្លឹកឆ្នោត**

បទល្មើសទិញសន្លឹកឆ្នោតត្រូវបានចែងក្នុងច្បាប់បោះឆ្នោត ប៉ុន្តែមិនមានការកំណត់សកម្មភាពអ្វីជា ការទិញសន្លឹកឆ្នោត

១០ អង្គការទាំងនោះរួមមាន ខុមហ្វ្រែល និកហ្វិច មជ្ឈមណ្ឌលសម្រាប់ការសិក្សាជាន់ខ្ពស់ និងវិទ្យាស្ថានជាតិប្រជាធិបតេយ្យ។

ឡើយ។ ក្នុងការបោះឆ្នោតកន្លងមកមានគណបក្សនយោបាយធ្វើការចែកអំណោយជាបាក់កាស និងសម្ភារៈ ដល់អ្នកបោះឆ្នោតក្នុងយុទ្ធនាការឃោសនាបោះឆ្នោត ប៉ុន្តែមិនមានការចោទប្រកាន់ ឬផ្តន្ទាទោសជនល្មើសទេ ។

■ **ការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយ**

ប្រព័ន្ធផ្សព្វផ្សាយរបស់រដ្ឋ និងឯកជន បានផ្សព្វផ្សាយព័ត៌មាន ស្តីពីសកម្មភាពរបស់គណបក្សកាន់ អំណាចយ៉ាងច្រើនលើសលប់បំផុត។ គ.ជ.ប មិនអាចធានាគោលការណ៍សមភាព និងយុត្តិធម៌ក្នុងការ បោះឆ្នោតក្នុងការផ្តល់ឱកាស ដល់គ្រប់គណបក្សនយោបាយទាំងអស់ ដើម្បីប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយបើសិនជាគោលការណ៍ណែនាំស្តីពីការប្រើប្រាស់ ប្រព័ន្ធផ្សព្វផ្សាយ មិនត្រូវបានដាក់បញ្ចូលទៅក្នុងបទបញ្ជា និងនីតិវិធីបោះឆ្នោត ក្នុងន័យចាប់បង្ខំឱ្យគោរពតាមគោលការណ៍ច្បាប់។

■ **អព្យាក្រឹតភាពរបស់មន្ត្រីរាជការស៊ីវិល កងនគរបាលជាតិ កងយោធពលខេមរភូមិន្ទ មន្ត្រីតុលាការ មេភូមិ**

មានមន្ត្រីនគរបាល និងយោធាជាន់ខ្ពស់មួយចំនួន បានធ្វើសកម្មភាពគណបក្សនយោបាយយ៉ាងចំហ ក្នុងការគាំទ្រ គណបក្សកាន់អំណាចក្នុងរូបភាពចុះមូលដ្ឋាន ពង្រឹងគណបក្ស ចុះសំណេះសំណាលជាមួយមន្ត្រី គណបក្សមូលដ្ឋាន ការកសាងទីស្នាក់ការគណបក្សជាដើម ដែលផ្ទុយនឹងគោលការណ៍អព្យាក្រឹតភាពកំណត់ ដោយច្បាប់រួចហើយ។

នៅថ្នាក់មូលដ្ឋាន មេភូមិ មេឃុំ និងអជ្ញាធរដែនដីនៅតែចូលរួមយ៉ាងសកម្មក្នុងសកម្មភាពឃោសនារបស់គណបក្សនយោបាយ ហើយរហូតមានការគំរាមកំហែងប្រជាពលរដ្ឋដែលមាននិន្នាការមិនស្រប និងគណបក្សរបស់ខ្លួនផង។ គោលការណ៍អព្យាក្រឹតភាពនេះគួរត្រូវបានពង្រឹង និងធានាដោយ គ.ជ.ប។

■ **បណ្តឹងទាក់ទងនឹងការបោះឆ្នោត**

ការចាត់ចែងទទួល និងដោះស្រាយពាក្យបណ្តឹងបោះឆ្នោត នៅតែបន្តជួបឧបសគ្គ។ ការចារបដិសេធទៅលើ បណ្តឹងដោយមន្ត្រី គ.ជ.ប គ្រាន់តែលើកឡើងថា គ្មានភស្តុតាងគ្រប់គ្រាន់នៅតែជាលេសក្នុងការ បដិសេធពាក្យបណ្តឹង។ ម្យ៉ាងទៀត គជប នៅតែពុំអាចពង្រឹងយន្តការស៊ើបអង្កេតដែលមានលក្ខណៈវិជ្ជាជីវៈ និងនីត្យានុកូលដើម្បីធ្វើការសាកសួរ យកចម្លើយបន្ថែម ពីគូភាគី និងការប្រមូលភស្តុតាង មុនឈានដល់ ដំណាក់ការបើកសវនាការសម្រេចសេចក្តី។

---

តមកពីទំព័រទី៦

## សង្ខេបលទ្ធផលការងារសំខាន់ៗរបស់ខុមហ្វ្រែល ឆ្នាំ២០០៧

កាត់បន្ថយភាពភ័យខ្លាចក្នុងចំណោមប្រជាពលរដ្ឋ នៅតាមស្ថានីយ៍បោះឆ្នោត នៅពេលពួកគេចូលរួមបោះឆ្នោត។

ការបោះឆ្នោតក្រុមប្រឹក្សាឃុំ-សង្កាត់ឆ្នាំ២០០៧ បានប្រព្រឹត្តទៅក្នុងលក្ខណៈប្រសើរឡើង និងមានការអនុវត្តលក្ខណៈបច្ចេកទេសបានល្អជាងការបោះឆ្នោតមុនៗ។ លទ្ធផលនេះគឺដោយសារការចែករំលែកចូលរួមពី សំណាក់អង្គការសង្កេតការណ៍បោះឆ្នោតមួយចំនួន។

ដោយសារបណ្តឹងពាក់ព័ន្ធនឹងនីតិវិធីស្មុគស្មាញ ក្នុងការពិនិត្យមើលបញ្ជីអ្នកបោះឆ្នោត នៅតាមស្ថានីយ៍បោះឆ្នោត គ.ជ.ប បានបន្ថែមមន្ត្រីបោះឆ្នោតម្នាក់ទៀត នៅក្រៅស្ថានីយ៍បោះឆ្នោតនីមួយៗ ដើម្បីជួយដល់អ្នកបោះឆ្នោត ហើយបានផ្តល់សន្លឹកព័ត៌មានអ្នកបោះឆ្នោត ដើម្បីជួយសម្រួលអ្នកបោះឆ្នោតនូវទិន្នន័យរបស់ពួកគេនៅពេល បោះឆ្នោត ទោះបីជាប្រព័ន្ធថ្មីនេះមិនមានប្រសិទ្ធភាពខ្លាំងក៏ដោយ។ មន្ត្រីខ្លះនៅតែមានការរើសអើងចំពោះអ្នកបោះឆ្នោត។

លទ្ធផលជាវិជ្ជមាននៃការចុះឈ្មោះអ្នកបោះឆ្នោត ពីខែកញ្ញា ដល់ តុលា ឆ្នាំ ២០០៦ និង ២០០៧ គឺអ្នកចុះឈ្មោះបោះឆ្នោតថ្មីចំនួនច្រើនជាង ២ លាននាក់។ គ.ជ.ប បានឆ្លើយតបនឹងសំណូមពររបស់អង្គការខុមហ្វ្រែល និងអ្នកពាក់ព័ន្ធផ្សេងទៀតក្នុងការបោះឆ្នោត ដើម្បីពន្យារពេលចុះឈ្មោះអ្នកបោះឆ្នោត ដូច្នេះ គ.ជ.ប បានសម្រេច បង្កើនចំនួនក្រុមចល័ត ដែលធ្វើការចុះឈ្មោះអ្នកបោះឆ្នោត ហើយបានពន្យាររយៈពេលចុះឈ្មោះបួនថ្ងៃថែម

ទៀត នៅតាមតំបន់មួយចំនួន ឆ្លើយតបតាមការបារម្ភរបស់ខុមហ្វ្រែល អង្គការសង្កេតការណ៍បោះឆ្នោត និងគណបក្សនយោបាយ ព្រមទាំងប្រជាពលរដ្ឋ ដែលមិនទាន់បានចុះឈ្មោះ។

មានការកើនឡើងគួរឱ្យជឿជាក់នៅក្នុងការចូលរួមសកម្មភាព និងលំហនយោបាយ ជាពិសេស នៅតាមសហគមន៍ដាច់ស្រយាល។ ប្រមាណ ៩០%នៃឃុំ-សង្កាត់ចំនួន ១៦២១ មានសមាជិកក្រុមប្រឹក្សាមកពីគណបក្ស ផ្សេងៗគ្នា ពោលគឺទាំងគណបក្សកាន់អំណាច និងគណបក្សជំទាស់។ ទោះជាយ៉ាងណា គណបក្សតែមួយផ្តាច់មុខ នៅតែមាននៅក្នុងឃុំចំនួន ១៦៦ (ធៀបនឹងចំនួន ១៤៨ នូវឃុំដូចគ្នានេះនៅឆ្នាំ ២០០២) ដោយគណបក្សកាន់ អំណាចទទួលបានអាសនៈទាំងអស់។ មានតែឃុំចំនួន ២៦ ប៉ុណ្ណោះ ក្នុងចំណោមឃុំ-សង្កាត់សរុប ១៦២១ ដែល មានមេឃុំមកពីគណបក្សជំទាស់។ សកម្មភាពគួរឱ្យកត់សម្គាល់មួយចំនួនរបស់គណបក្សនយោបាយគឺការជ្រើសរើសបេក្ខជនក្រុមប្រឹក្សាឃុំ-សង្កាត់ ដែលបង្កើត និងផ្តល់អាទិភាពដល់បេក្ខនារី និងការរៀបចំយុទ្ធសាស្ត្ររបស់ពួកគេ សម្រាប់ការចូលរួមនៅក្នុងការបោះឆ្នោត។ អង្គការខុមហ្វ្រែល និងអ្នកពាក់ព័ន្ធការបោះឆ្នោតផ្សេងទៀតបន្តតស៊ូមតិ ដើម្បីឱ្យមានបុគ្គលឯករាជ្យ ឈរឈ្មោះជាបេក្ខជននៅក្នុងការបោះឆ្នោត ឬសម្រាប់សមាគមសហគមន៍ មូលដ្ឋាន ឱ្យជ្រើសរើសបេក្ខជនដោយខ្លួនពួកគេ។

មានការកើនឡើងតិចតួច ចំពោះការចូលរួមរបស់ស្ត្រីនៅក្នុងវិស័យនយោបាយ ក្នុងការបោះឆ្នោតឃុំ-សង្កាត់ ២០០៧។ សមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់ចំនួន ១.៦៦២ នាក់ស្មើនឹង ១៤,៦៤% គឺជាស្ត្រី ក្នុងចំណោម សមាជិកសរុបទូទាំងប្រទេសចំនួន ១១.៣៩៣រូប ប្រៀបធៀបនឹងចំនួន ៩២០ នាក់ ស្មើនឹង ៨% នៃចំនួនសរុប ១១.២៦១ រូប នៅឆ្នាំ ២០០២។ ដូចនៅក្នុងការបោះឆ្នោតមុនៗដែរ មេឃុំ-សង្កាត់ស្ទើរតែទាំងអស់គឺជាបុរស ពោលគឺមានមេឃុំស្ត្រីចំនួន ៣៤ រូប នៅឆ្នាំ ២០០២ និង ចំនួន ៦៧ រូប នៅឆ្នាំ ២០០៧។ ដូច្នេះនៅតែមានកង្វះ សមភាពយេនឌ័រគឺឱ្យកត់សម្គាល់។ នៅក្នុងសង្គមកម្ពុជា ស្ត្រីមានចំនួនច្រើនជាងបុរសបន្តិចបន្តួច ដែលជាក់ស្តែងគឺ មានភាគរយស្ត្រីកាន់តែធំភាគច្រើននៅតាមតំបន់ដាច់ស្រយាល ដោយសារតែបុរសធ្វើអន្តោប្រវេសន៍ទៅទីក្រុង ហើយនិងកម្រិតអត្រាមរណៈរបស់បុរសខ្ពស់ជាង ដោយសារសង្គ្រាមកន្លងមក។

ការចូលរួមរបស់យុវជនមានការកើនឡើងនៅក្នុងដំណើរការសង្កេតការបោះឆ្នោតឆ្នាំ ២០០៧។ អង្គការ ខុមហ្វ្រែល សហការជាមួយអង្គការសង្កេតការណ៍បោះឆ្នោតនានា ជាពិសេស អង្គការយុវជន បានជំរុញយ៉ាងខ្លាំងដល់យុវជនឱ្យចូលរួមនៅក្នុងសកម្មភាពបោះឆ្នោត។ ជាលទ្ធផល អ្នកសង្កេតការណ៍របស់ខុមហ្វ្រែល ចំនួន ៦.៣៩៧ នាក់ ស្មើនឹង ៦៧% នៃចំនួនអ្នកសង្កេតការណ៍សរុបគឺមានអាយុទាបជាង ៣០ ឆ្នាំ។ យុវជនសង្កេតការណ៍ចំនួន ៧០០ នាក់មកពីក្រុមប្រឹក្សាយុវជនកម្ពុជា ហើយបានចូលរួមយ៉ាងសកម្មនៅក្នុងការបោះឆ្នោតឆ្នាំ ២០០៧ នេះ ដូចជា ការចូលរួមចែកប័ណ្ណព័ត៌មានអ្នកបោះឆ្នោត ការចែកផ្សាយព័ត៌មានពាក់ព័ន្ធនឹងការបោះឆ្នោតឱ្យដល់អ្នកបោះឆ្នោត ហើយធ្វើការសង្កេតការបោះឆ្នោត។ អ្នកសង្កេតការបោះឆ្នោតយុវជនមកពីសមាគមយុវជនខ្មែរ តំណាង ឱ្យ ៩០%នៃចំនួនអ្នកសង្កេតការណ៍សរុប ៤៩១។ ភាគច្រើនបានចូលរួមដោយស្ម័គ្រចិត្តក្នុងសកម្មភាពបោះឆ្នោត ដោយមិនទាមទារកម្រៃ ហើយមានការតាំងចិត្តខ្ពស់ ក្នុងការធ្វើការអស់កម្លាំងកាយចិត្ត។

គណនេយ្យភាពរបស់ក្រុមប្រឹក្សាឃុំ-សង្កាត់ក៏មានការកើនឡើងផងដែរ ក្នុងការដោះស្រាយបញ្ហានៅ មូលដ្ឋាន តាមរយៈវេទិការសាធារណៈនៅតាមមូលដ្ឋានរបស់ខុមហ្វ្រែល។ បញ្ហាចំនួន ៤៣,៥% នៃបញ្ហា ដែល លើកឡើងដោយប្រជាពលរដ្ឋនៅមូលដ្ឋាននោះ ត្រូវបានឆ្លើយតបតាមការត្រូវការរបស់អ្នកភូមិ។ ភាគរយចំនួន ៨,៥១% ត្រូវបានដោះស្រាយ និង ៧,៧៥%ត្រូវបានកត់សម្គាល់ថា អាចនឹងត្រូវដោះស្រាយ។ ចំនួន ១០,៦៣% បានទទួលការសន្យាថាដោះស្រាយ និងធ្វើការជាបន្តបន្ទាប់ជាមួយនឹងអាជ្ញាធរថ្នាក់ស្រុក ខេត្ត និងរដ្ឋបាលកណ្តាល។

ការចូលរួមរបស់ប្រជាពលរដ្ឋចំពោះអភិបាលកិច្ចមូលដ្ឋានក៏មានការកើនឡើងផងដែរ នៅតាមតំបន់គោល ដៅរបស់ខុមហ្វ្រែល។ វេទិកាសាធារណៈ និងការបណ្តុះបណ្តាលរបស់ខុមហ្វ្រែលស្តីពីការតស៊ូមតិនៅមូលដ្ឋាន បាន ចូលរួមចំណែកដល់ការជ្រើសរើសអ្នកភូមិចំនួន ៤៧ នាក់ (ស្ត្រី ១៦ នាក់) ជាអ្នកសង្កេតស្ម័គ្រចិត្តដែលទទួលបាន ការបណ្តុះបណ្តាល ដើម្បីសង្កេតមើលការអនុវត្តការងាររបស់ក្រុមប្រឹក្សាឃុំ-សង្កាត់ និងចូលរួមក្នុងកិច្ចប្រជុំនានា របស់ក្រុមប្រឹក្សាឃុំ។ ចំនួនសរុបនៃអ្នកសង្កេតការណ៍ខុមហ្វ្រែលនៅតាមមូលដ្ឋាន បានកើនឡើងជាបណ្តើរៗ នៅកម្រិតឃុំ-សង្កាត់។ អ្នក សង្កេតការទាំងនេះដើរតួនាទីសំខាន់មួយក្នុងការចូលរួមភារកិច្ចនៅតាមមូលដ្ឋាន។ អាជ្ញាធរមូលដ្ឋាន មន្ត្រីជាប់ឆ្នោត និងសមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់កាន់តែមានការទទួលខុសត្រូវចំពោះអ្នក បោះឆ្នោត ក្នុងការឆ្លើយតបនឹងសំណូមពររបស់អ្នកបោះឆ្នោត ដូចជាសាងសង់ផ្លូវ និងដោះស្រាយបញ្ហានៅតាមមូលដ្ឋានជូនដល់ប្រជាជន។

**អង្គការខុមហ្វ្រែល**

*តមកពីទំព័រទី១០*

## ការវាយតម្លៃរបស់យុវជនអំពីការបំពេញរបស់រាជរដ្ឋាភិបាលកម្ពុជា...

**គណបក្សជាប់ឆ្នោតក្នុងការអនុវត្តវិស័យបណ្តុះបណ្តាល និង ការបង្កើតការងារនៅក្នុងមណ្ឌលកំពង់ចាម ដែលត្រូវបានដាក់ពិន្ទុដោយយុវជនក្នុងវេទិកានេះគឺ ២,៤៣។ ពិន្ទុនេះមានន័យថា កំរិតពេញចិត្តនៅត្រឹមតិចតួចបំផុត។**

អ្នកចូលរួមជាយុវជន បានផ្តល់យោបល់ទៅលើអាទិភាពនៃវិស័យបណ្តុះបណ្តាល និងការបង្កើតការងារដើម្បីឱ្យរាជរដ្ឋាភិបាល ឬគណបក្សនយោបាយជាប់ឆ្នោតខិតខំបន្តអនុវត្តការសន្យា ហើយគណបក្សចូលរួមប្រកួតប្រជែងការបោះឆ្នោតជាតិឆ្នាំ ២០០៨ ក៏គួរយកចិត្តទុកដាក់យកយោបល់នេះ ដើម្បីដាក់បញ្ចូលទៅក្នុងកម្មវិធីនយោបាយរបស់ខ្លួន។ ចំណុចជា អាទិភាពទាំងនោះមានដូចជា:

- **ត្រូវពង្រឹងគុណភាពអប់រំ និងបណ្តុះបណ្តាលដែលស្របជាមួយតម្រូវការទីផ្សារ**
- **បង្កើនបទពិសោធន៏ការងារ ដល់យុវជនតាមរយៈការបង្កើតបណ្តាញមណ្ឌលលំហាត់ការឱ្យបានច្រើន**
- **គ្រប់គ្រងពលករបរទេសខុសច្បាប់ធ្វើការងារនៅកម្ពុជា ដោយពង្រឹងការអនុវត្តច្បាប់អន្តោប្រវេសន្តឱ្យបានម៉ឺងម៉ាត់**
- **រៀបចំផែនការ និងការបណ្តុះបណ្តាលសំរាប់ទីផ្សារការងារឱ្យចំនឹងទីផ្សារក្នុងខេត្តកំពង់ចាមដូចជាជំនាញទាក់ទងនឹងកៅស៊ូ**
- **ត្រូវរកទីផ្សាការងារតាមរយៈការបង្កើនការវិនិយោគ និងពង្រឹងអភិបាលកិច្ចល្អ និងសន្តិសុខ។**

### ខេត្តកណ្តាល

**១- ការអនុវត្តគោលនយោបាយសំដៅបង្កើតការងាររបស់រាជរដ្ឋាភិបាលៈ**



អ្នកចូលរួមវេទិកាជាយុវជនបានឱ្យពិន្ទុសរុបជាមធ្យម **២,៥៦** ដែលស្ថិតនៅក្នុងកំរិត**ពេញចិត្តត្រឹមតិចតួចបំផុត** ប៉ុណ្ណោះ។ ក្នុងនោះ អ្នកផ្តល់ពិន្ទុ **១** (មិនពេញចិត្តសោះ) គឺមិនមានទេ។ អ្នកផ្តល់ពិន្ទុ **២** (ពេញចិត្តតិចតួច បំផុត) មាន **៥៥%** អ្នកផ្តល់ពិន្ទុ **៣** (ពេញចិត្តគួរសម) មាន **៣៨%** អ្នកផ្តល់ពិន្ទុ **៤** (ពេញចិត្តច្រើន) មាន **៤%** និងអ្នកផ្តល់ពិន្ទុ **៥** (ពេញចិត្តខ្លាំងណាស់) មានតែ**៣%**។ការពិភាក្សាបានរកឃើញថានៅពេលបច្ចុប្បន្ននេះ នៅខេត្តកណ្តាលមានរោងចក្រ ប្រមាណ ៨០ ហើយមានកម្មករជាង ៦០.០០០ នាក់។ ទោះបីយ៉ាងណា ការពិភាក្សាក៏បានលើកឡើងផងដែរថា បញ្ហាអំពើ ពុករលួយបានរាំងស្ទះដល់ការ ធ្វើវិនិយោគរបស់អ្នកវិនិយោគទុន ហើយរាជរដ្ឋាភិបាលត្រូវខិតខំស្វែងរកទីផ្សារថែមទៀត សម្រាប់ការងារយុវជន។

**២- ការពង្រឹងនូវការអនុវត្តច្បាប់ការងារ និងអនុសញ្ញាអន្តរជាតិនានាដើម្បីធានានូវសិទ្ធិ និងផលប្រយោជន៏របស់កម្មករនិយោជិត និងនិយោជកៈ**

អ្នកចូលរួមវេទិកាជាយុវជនបានឱ្យពិន្ទុសរុបជាមធ្យម **២,៦០** គឺស្ថិតនៅក្នុងកំរិត **ពេញចិត្តត្រឹមតិចតួចបំផុត**។ ក្នុងនោះ អ្នកផ្តល់ពិន្ទុ **១** (មិនពេញចិត្តសោះ) មាន **៣%** អ្នកផ្តល់ពិន្ទុ **២** (ពេញចិត្តតិចតួចបំផុត) មាន **៤៦%** អ្នកផ្តល់ពិន្ទុ **៣** (ពេញចិត្តគួរសម) មាន **៤១%** អ្នកផ្តល់ពិន្ទុ **៤** (ពេញចិត្តច្រើន) មាន **៩%** និងអ្នកផ្តល់ពិន្ទុ **៥** (ពេញចិត្តខ្លាំងណាស់) មាន **១%**។ ការពិភាក្សា បានរកឃើញថា ការធ្វើកូដកម្មដោយកម្មកររោងចក្រមានការធ្លាក់ចុះក្នុងឆ្នាំ ២០០៧ បើប្រៀបធៀប ទៅនឹងឆ្នាំមុនៗ (ឆ្នាំ ២០០៧ មានកូដកម្មប្រហែលជា២០)។ ទោះបីយ៉ាងណា មានមតិផ្ទុយគ្នាចំពោះមូលហេតុនៃ ការធ្លាក់ចុះចំនួនកូដកម្មនេះ។ អនុប្រធានមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តកណ្តាល លោក **គីម សារ៉ា** បានលើកឡើងថាចំនួនកូដកម្មមានការធ្លាក់ចុះក៏ដោយសារនិយោជក និងនិយោជិតភាគច្រើនមានការយល់ និងអនុវត្តច្បាប់បានល្អប្រសើរ។ ទោះបីយ៉ាងណា អ្នកតំណាងរាស្ត្រ **ចាន់ ចេង** បានមានប្រសាសន៏ថា ចំនួនកូដកម្មនេះ បានធ្លាក់ចុះដោយសារតែមានការគំរាម និងគាបសង្កត់ពីនិយោជក។ ឧទាហរណ៏ ដូចជាបើកម្មករណាហ៊ានធ្វើកូដកម្ម នឹងត្រូវបញ្ឈប់ពីការងារជាដើម។ ចំណែកអ្នកតំណាងរាស្ត្រ **ខៀវ សន** បានលើកឡើងថាការយល់ដឹងពីច្បាប់ការងារ ទាំងនិយោជក និងនិយោជិតនៅមានកម្រិតនៅឡើយ។

**៣- ការបង្កើតបណ្តាញបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ ផ្សារភ្ជាប់នឹងមជ្ឈមណ្ឌលសម្រាប់ជួយរកការងារធ្វើឱ្យយុវជនៈ**

អ្នកចូលរួមវេទិកាជាយុវជនបានឱ្យពិន្ទុសរុបជាមធ្យម **២,៦២** ដែលស្ថិតនៅក្នុងកំរិត**ពេញចិត្តត្រឹមតិចតួចបំផុត**។ ក្នុងនោះ អ្នកផ្តល់ពិន្ទុ **១**(មិនពេញចិត្តសោះ) មាន **៧%** អ្នកផ្តល់ពិន្ទុ **២** (ពេញចិត្តតិចតួចបំផុត) មាន **៤១%** អ្នកផ្តល់ពិន្ទុ **៣** (ពេញចិត្តគួរសម) មាន **៣៧%** អ្នកផ្តល់ពិន្ទុ ៤ (ពេញចិត្តច្រើន) មាន **១២%** និងអ្នកផ្តល់ពិន្ទុ **៥** (ពេញចិត្តខ្លាំងណាស់) មាន **៣%**។

ការពិភាក្សាបានរកឃើញថា នៅខេត្តកណ្តាលមានមជ្ឈមណ្ឌលបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ ហើយគិតមកដល់ឆ្នាំ ២០០៧ មានការបណ្តុះបណ្តាលសិស្សចំនួន ៩៤០ នាក់ នូវជំនាញកសិកម្ម អគ្គិសនី បរិក្ខារត្រជាក់...។ ក៏ប៉ុន្តែនៅខេត្តកណ្តាលមិនទាន់ មានការិយាល័យផ្តល់ព័ត៌មានពីការងារនៅឡើយទេ។ អង្គវេទិកាបានលើកឡើងថា ការផ្សព្វផ្សាយពីព័ត៌មាន ទាក់ទងនឹងការបណ្តុះបណ្តាលរបស់រដ្ឋហាក់បីដូចជាមិនមានភាពទូលំទូលាយនោះទេ។

**៤- ការបង្កើតមជ្ឈមណ្ឌលបណ្តុះបណ្តាល និងផ្សព្វផ្សាយពលរដ្ឋវិជ្ជាដល់យុវជន និងការបង្កើតបណ្ណាល័យសាធារណៈបន្ថែមទៀតៈ**

អ្នកចូលរួមវេទិកាជាយុវជនបានឱ្យពិន្ទុសរុបជាមធ្យម **២,៣១** ដែលស្ថិតនៅក្នុងកំរិត **ពេញចិត្តត្រឹមតិចតួចបំផុត**។ ក្នុងនោះអ្នកផ្តល់ពិន្ទុ **១**(មិនពេញចិត្តសោះ) មាន **៧%** អ្នកផ្តល់ពិន្ទុ **២** (ពេញចិត្តតិចតួចបំផុត) មាន **៦៤%** អ្នកផ្តល់ពិន្ទុ **៣** (ពេញចិត្តគួរសម) មាន **២២%** អ្នកផ្តល់ពិន្ទុ ៤ (ពេញចិត្តច្រើន) មាន **៦%** និងអ្នកផ្តល់ពិន្ទុ **៥** (ពេញចិត្តខ្លាំងណាស់) មាន **១%**។ អង្គវេទិកាបានលើកឡើងថា នៅខេត្តកណ្តាលមិនសូវមានបណ្ណាល័យនោះទេ ហើយបណ្ណាល័យដែលមានស្រាប់ហើយ នោះក៏មិនសូវដំណើរការបានល្អដែរ។ លោក **ផេង សៅឆេង** បានឱ្យដឹងថា មានបណ្ណាល័យខ្លះនៅក្នុងសាលារៀន តែម៉ោងធ្វើការមិនច្បាស់លាស់ ហើយមិនសូវមានឯកសារសម្រាប់អាន។ បុគ្គលិកបម្រើការក៏មិនធ្វើការជាប់លាប់។

**៥-ការពង្រឹងការគ្រប់គ្រងពលករបរទេសនៅកម្ពុជាក្នុងទិសដៅដោះស្រាយការងារធ្វើ និងស្រូបយកបច្ចេកវិជ្ជាថ្មីៈ**

អ្នកចូលរួម វេទិកាជាយុវជនបានឱ្យពិន្ទុសរុបជាមធ្យម **២,៧៩** ដែលស្ថិតនៅក្នុងកំរិត **ពេញចិត្តត្រឹមតិចតួចបំផុត**។ ក្នុងនោះ អ្នកផ្តល់ពិន្ទុ **១**(មិនពេញចិត្តសោះ) មាន **៧%** អ្នកផ្តល់ពិន្ទុ **២**(ពេញចិត្តតិចតួចបំផុត) មាន **៣៩%** អ្នកផ្តល់ ពិន្ទុ **៣**(ពេញចិត្តគួរសម) មាន **៣២%** អ្នកផ្តល់ពិន្ទុ **៤**(ពេញចិត្តច្រើន) មាន **១៦%** និងអ្នកផ្តល់ពិន្ទុ **៥**(ពេញចិត្តខ្លាំងណាស់) មាន **៦%**។

អង្គវេទិកាបានលើកឡើងថាអាជ្ញាធរខេត្តកណ្តាលជាពិសេសមន្ទីរការងារមានការគ្រប់គ្រងពលករបរទេសស្របច្បាប់បានល្អដែល មានប្រមាណ ៤៥០ នាក់នៅទូទាំងខេត្ត។ ទោះបីយ៉ាងណាមានការលើកឡើងថា មន្ទីរការងារមិនអាចគ្រប់គ្រងពលករបរទេស មួយចំនួនដែលមកពីប្រទេសជិតខាងហើយធ្វើការដូចជាក្នុងវិស័យសំណង់ជាដើម។

**ជាសរុប ពិន្ទុជាមធ្យមនៃការបំពេញរបស់រដ្ឋាភិបាល ឬគណបក្សជាប់ឆ្នោតក្នុងការអនុវត្តវិស័យបណ្តុះបណ្តាល និង ការបង្កើតការងារនៅក្នុងមណ្ឌលកណ្តាល ដែលត្រូវបានដាក់ពិន្ទុដោយយុវជនក្នុងវេទិកានេះគឺ ២,៥៦។ ពិន្ទុនេះមានន័យ ថា កំរិតពេញចិត្តនៅត្រឹមតិចតួចបំផុត។**

អ្នកចូលរួមជាយុវជនក្នុងមណ្ឌលកណ្តាល បានផ្តល់យោបល់ទៅលើអាទិភាពនៃវិស័យបណ្តុះបណ្តាល និងការបង្កើតការងារ ដើម្បីឱ្យរាជរដ្ឋាភិបាល ឬគណបក្សនយោបាយជាប់ឆ្នោតខិតខំបន្តអនុវត្តការសន្យា ហើយគណបក្សចូលរួមប្រកួតប្រជែងការបោះឆ្នោត ជាតិឆ្នាំ ២០០៨ ក៏គួរយកចិត្តទុកដាក់យកយោបល់នេះ ដើម្បីដាក់បញ្ចូលទៅក្នុងកម្មវិធីនយោបាយរបស់ខ្លួន។ ចំណុចជាអាទិភាព ទាំងនោះមានដូចជាៈ

- **ត្រូវពង្រឹងគុណភាពអប់រំ និងបណ្តុះបណ្តាលដែលស្របជាមួយតម្រូវការទីផ្សារ**
- **គ្រប់គ្រងពលករបរទេសខុសច្បាប់ធ្វើការងារនៅកម្ពុជា ដោយពង្រឹងការអនុវត្តច្បាប់អន្តោប្រវេសន្តឱ្យបានម៉ឺងម៉ាត់**
- **ត្រូវរកទីផ្សាការងារតាមរយៈការបង្កើនការវិនិយោគ ពង្រឹងអភិបាលកិច្ចល្អ សន្តិសុខ និងបំបាត់អំពើពុករលួយ។**
- **ត្រូវឱ្យមានការចូលនិវត្តន៍របស់មន្ត្រីចាស់ៗដែលគ្រប់អាយុចូលនិវត្តន៍ ហើយការជ្រើសរើសបុគ្គលិកឱ្យបម្រើការងាររដ្ឋគួរត្រូវផ្សព្វផ្សាយឱ្យបានទូលំទូលាយតាមប្រព័ន្ធផ្សព្វផ្សាយរដ្ឋ។**

*តមកពីទំព័រទី១២*

# ឃ្លាំមើលសភា និង តំណាងរាស្ត្រសំរាប់ខែធ្នូ ២០០៧-កុម្ភៈ ២០០៨

## តំណាងរាស្ត្រការពារការងារគណបក្សខ្លួននៅក្នុងសម័យប្រជុំសភា



អ្នកតំណាងរាស្ត្រ **ជាម យៀប** មកពីគណបក្សប្រជាជនកម្ពុជាបានឡើងការពារមន្ត្រីរាជរដ្ឋាភិបាលរបស់ខ្លួនថាធ្វើការដោយឯករាជ្យ ។ អ្នកតំណាង រាស្ត្ររូបនេះបានបន្តទៀតថា គណបក្សប្រជាជនកម្ពុជាបានអនុវត្តតាមលទ្ធិប្រជាធិបតេយ្យពេញលេញ ហើយគ្រប់ មេភូមិដែលគណបក្សប្រជាជនកម្ពុ ជាបានជ្រើសរើសគឺជាមនុស្សមានសម្ថភាព លទ្ធភាព អត្តចរិតល្អ និងគោរពអនុវត្តតាមច្បាប់ទំលាប់ត្រឹម ត្រូវ។ ការឡើងការពារនេះ បានធ្វើឡើង នៅក្នុងកិច្ចពិភាក្សា និងអនុម័តយល់ព្រមលើសេចក្តីព្រាងច្បាប់ស្តីពីនីតិវិធីនៃការពិន័យស៊ីវិល និងបន្ទាប់ពីអ្នកតំណាងរាស្ត្រ **សម រង្ស៊ី** ប្រធានគណបក្ស ប្រឆាំង បានធ្វើការរិះគន់ខ្លាំងៗទៅលើអំពើពុករលួយ និង មិនឯករាជ្យរបស់អាជ្ញាធរមូលដ្ឋានមកពីគណបក្សប្រជាជនកម្ពុជា ជាពិសេសគឺមេភូមិរបស់គណបក្សប្រជាជនកម្ពុជា ។ អ្នកតំណាងរាស្ត្រ**សមរង្ស៊ី** បានលើក ឡើងថាអាជ្ញាធរមូលដ្ឋានបានប្រព្រឹត្តអំពើពុករលួយក្នុងការបញ្ជាក់លិខិតស្នាមសៀវភៅគ្រួសារ អត្រានុកូលដ្ឋាន សំបុត្រកំណើត និងរើស អើងនយោបាយដោយមិនបញ្ជាក់លំនៅដ្ឋានដល់ប្រជាពលរដ្ឋ និងមិនផ្តល់លិខិតស្នាមលិខិតបញ្ជាក់ផ្សេងៗ ឬអត្តសញ្ញាណប័ណ្ណដល់កម្មករ ដែលជាហេតុធ្វើអោយពួកគេមិនអាចបោះឆ្នោតក្រុមប្រឹក្សាឃុំសង្កាត់ឆ្នាំ២០០៧បាន ព្រោះកម្មករមិនគាំទ្រគណបក្សកាន់អំណាច ។ ទោះបី យ៉ាងណា ការលើកឡើងរបស់តំណាងរាស្ត្រ **សម រង្ស៊ី** ត្រូវបានអ្នកតំណាងរាស្ត្រមកពីគណបក្សហ៊្វុនស៊ិន ប៉ិច **ខៀវ សន** ចោទថាឯកឧត្តម **សម រង្ស៊ី** បានយកវេទិកាពិភាក្សា និងអនុម័តសេចក្តីព្រាងច្បាប់របស់រដ្ឋសភាមកធ្វើជាវេទិកានយោបាយ ។ លោកបានបញ្ជាក់ថា *"វាគ្មិនខ្លះបានយកវេទិកានេះ មកធ្វើជាវេទិកានយោបាយ....គ្រាន់តែនិយាយប្រាវៗរួច ហើយចេញបាត់ ។ "* ក្នុងនាមឯកឧត្តម ជាតំណាងរាស្ត្រមួយរូប ឯកឧត្តមមិនចង់អោយមានការយកសម័យប្រជុំពេញអង្គសភាមកធ្វើប្រជាភិថុតិយកសំឡេងឆ្នោតមុនយុទ្ធធានាការឃោសនា បោះឆ្នោត យ៉ាងដូច្នេះនោះទេ ព្រោះឯកឧត្តមយល់ឃើញថា ទង្វើបែបនេះ ជាអំពើដ៏អាក្រក់មួយ ។

## សុន ឆ័យ ស្នើនាយករដ្ឋមន្ត្រីបញ្ឈប់ការតែងតាំងទីប្រឹក្សា



អ្នកតំណាងរាស្ត្រ **សុន ឆ័យ** មកពីគណបក្ស**សមរង្ស៊ី** បានស្នើសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** បញ្ឈប់ការតែងតាំងទីប្រឹក្សាដែលមាន ឋានៈស្មើរដ្ឋមន្ត្រី ឬរដ្ឋលេខាធិការជាបន្ទាន់ និងសូមផ្ញើបញ្ជីឈ្មោះទីប្រឹក្សាដែលទទួលប្រាក់បៀវត្សរ៍ពីរាជរដ្ឋាភិបាល ទាំងអស់មករដ្ឋសភា ។ នៅក្នុង សារលិខិតចុះថ្ងៃទី១៨ កុម្ភៈ អ្នកតំណាងរាស្ត្រ **សុន ឆ័យ** បានឱ្យដឹងថា រាជរដ្ឋាភិបាលអាណត្តិទី៣នេះ មានការតែងតាំងឈ្មួញជាអ្នករកស៊ី និងបុគ្គលិកមន្ត្រីរាជការ រួមទាំងគណបក្សផ្សេងដែលរត់ទៅចុះចូលជាច្រើនរូប ជាទីប្រឹក្សារាជរដ្ឋាភិបាល ក្នុងឋានៈជារដ្ឋមន្ត្រី និងរដ្ឋលេខាធិការ ដោយពុំដឹងមាន ចំនួនប៉ុន្មានរយនាក់ហើយនោះ និងមិនដឹងថាពួកគេទាំងនេះមានជំនាញខុសប្លែកគ្នាអ្វីខ្លះសម្រាប់ជួយដល់ការគ្រប់គ្រងប្រទេសប្រកបដោយអភិបាល កិច្ចល្អ និងនីតិរដ្ឋ ព្រោះរដ្ឋត្រូវចំណាយថវិការអស់ជាច្រើនជាប្រាក់បៀវត្សរ៍ដល់ពួកគេ ។ក្នុងលិខិតនោះក៏បានបន្តទៀតដែរថា មានពួកឈ្មួញខិលខូច មួយចំនួនដែលបានយកតួនាទីជាទីប្រឹក្សារបស់ថ្នាក់ដឹកនាំទៅប្រព្រឹត្តអំពើរំលោភច្បាប់ផ្សេងៗ ដូចជា សកម្មភាពរំលោភដីធ្លីរបស់ប្រជាពលរដ្ឋ ការរត់ពន្ធទំនិញ និងការមិនបង់ពន្ធជូនរដ្ឋជាដើមដែលបង្កការលំបាកដល់សមត្ថកិច្ចក្នុងការបង្ក្រាប ។ ទោះជាយ៉ាងណា សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** បានបដិសេធសំណើររបស់អ្នកតំណាង រាស្ត្រសុន ឆ័យ ដោយបញ្ជាក់ថា សម្តេច នឹងនៅតែបន្តការតែងតាំងអ្នកផ្តាច់ខ្លួនពីគណបក្សដទៃទាំងអស់ ចូលគណបក្សប្រជាជនកម្ពុជាអោយទទួលតំណែងផ្សេងៗក្នុងជួររាជរដ្ឋាភិបាល ។ សម្តេចបានមានប្រសាសន៍ក្នុងពិធីបុណ្យបញ្ចុះខ័ណ្ឌសីមា វត្តព្រៃក គង់រាជ្យ និងពិធីបើកការដ្ឋាន សាងសង់ស្ពាន ៥កន្លែង និងផ្លូវលំមួយខ្សែនៅស្រុកល្វាឯមខេត្តកណ្តាល កាលពីថ្ងៃទី ២១ ខែកុម្ភៈ ថា *" ឥឡូវ ប្រសិនបើមានអ្នកហ៊ាន ចាកចេញពីបក្ស ខ្ញុំ នឹងតែងតាំងពួកគេឡើងវិញ ។ ប្រសិនបើអ្នកជាសមាជិកនៃគណកម្មការអចិន្ត្រៃយ៍ ខ្ញុំនឹងតែងតាំង អ្នកជាទីប្រឹក្សារបស់រាជរដ្ឋា ភិបាល។ ខ្ញុំសូមផ្តាំត្រឡប់ទៅវិញ មកប៉ុន្មាន តែងតាំងទាំងអស់។ បើមក ១០០ តែងតាំងទាំង ១០០"* ។ គួរបញ្ជាក់ដែរ ថានាពេលថ្មីនេះៗ សម្តេច **ហ៊ុន សែន** បានធ្វើការតែងតាំងទីប្រឹក្សាជាច្រើននាក់ដែលមកពីគណបក្សផ្សេងៗហើយចុះចូលជាមួយគណបក្សប្រជាជនកម្ពុជា និងបានតែងតាំងអភិបាលខេត្តក្រុងនានាជាទីប្រឹក្សាឋានៈស្មើរដ្ឋមន្ត្រីផងដែរ ។

## អគ្គលេខាធិការរដ្ឋសភាៈ អ្នកតំណាងរាស្ត្រនៅមានភាពក្មេងខ្ចីក្នុងការអនុវត្តតួនាទីរបស់ខ្លួន

អគ្គលេខាធិការរដ្ឋសភាឯកឧត្តម **ឡេង ប៉េងឡុង** បានថ្លែងថាៈ *"នៅក្នុងបណ្តាភារៈទាំង៣ របស់ សមាជិករដ្ឋសភា........ មានភារកិច្ចពីរគឺ ការត្រួតពិនិត្យរាជរដ្ឋាភិបាល និងការអនុវត្តតួនាទីជាតំណាងឃើញថា ពុំទាន់បានរៀបចំបានល្អប្រសើរនៅឡើយ។ "* ឯកឧត្តម

**ឡេង ប៉េងឡុង** បានថ្លែងបែបនេះនៅក្នុងវេទិកាប្រធាន ស្តីពី បទពិសោធន៍នៃការអនុវត្តរបស់គម្រោងគាំទ្រនីតិបញ្ញត្តិ កម្ពុជាកាណាដា។ ឯកឧត្តម **ឡេង ប៉េងឡុង**បានបញ្ជាក់បន្ថែមទៀតថា ចំពោះការងារទាំងពីរខាងលើនេះ អ្នកតំណាងរាស្ត្រនៅមានបទពិសោធន៍ក្មេងខ្ចី ព្រមទាំងខ្វះខាតមធ្យោបាយយ៉ាងច្រើន ហើយការិយាល័យតំណាងរាស្ត្រនៅតាមមណ្ឌលទាំង២៤ខេត្ត/ក្រុង ដែលមានភារកិច្ចសម្រួលដល់ការងាររបស់អ្នកតំណាងរាស្ត្រ និងសម្រួលដល់ការ ប្តឹងតវ៉ារបស់ប្រជាពលរដ្ឋ គឺមានតែឈ្មោះប៉ុណ្ណោះ និងមិនអាចបំពេញ ភារកិច្ចរបស់ខ្លួនឱ្យបានសមរម្យឡើយ។ **ខុមហ្វ្រែល** ក៏សង្កេតឃើញដែរថា ខណៈដែលការិយាល័យតំណាងរាស្ត្រនៅមណ្ឌលមួយចំនួនខ្វះសម្ភារៈដើម្បីធ្វើការបុគ្គលិកការិយាល័យតំណាងរាស្ត្រក៏មិនបានគោរពពេលវេលាធ្វើការដែរ ដូចជានៅមណ្ឌលកំពង់ស្ពឺជាដើម។

## អ្នកតំណាងរាស្ត្រស្នើឱ្យរាជរដ្ឋាភិបាលការពារបរិស្ថាន និងធម្មជាតិ ទោះបីវាមិនមែនជាតំបន់ការពារធម្មជាតិក៏ដោយ



នៅពេលដែលតំបន់ការពារធម្មជាតិទាំង២៣កន្លែងក្នុងប្រទេសមានច្បាប់ដើម្បីការពារ អ្នកតំណាងរាស្ត្រមួយចំនួនក៏បានស្នើដល់ **ក្រសួងបរិស្ថានឱ្យជួយពិនិត្យមើលបរិស្ថាន**នៅតំបន់ផ្សេងៗទៀតផងដែរ។ អ្នកតំណាងរាស្ត្រ **ម៉ោញ សាផាន មណ្ឌលកំពង់ចាម** បាន លើកឡើងពី**បញ្ហាជីកយករ៉ែមាស** ដោយមានការបាញ់ទឹកដែលជាហេតុនាំឱ្យមានដីហូរចូលបឹងព្រែក ហើយនាំឱ្យមានការប៉ះពាល់ដល់ ប្រជាពលរដ្ឋ ។ អ្នកតំណាងរាស្ត្រ **គី លំអង មណ្ឌលបាត់ដំបង**បានបន្ថែមទៀតថា មានក្រុមហ៊ុនរុករករ៉ែមាសខ្លះ មិនទាន់បានចាប់ផ្តើមផង ក៏ប៉ុន្តែបានបំផ្លាញបរិស្ថានរួចទៅហើយ ហើយមាន **រោងចក្រមួយចំនួននៅតែបង្ហូរជាតិពុលចូលទន្លេ** ។ អ្នកតំណាងរាស្ត្រមណ្ឌលព្រៃវែង **អ្នកអង្គម្ចាស់ក្សត្រីយ៍ ស៊ីសុវត្ថិ សន្តា** បានស្នើឱ្យក្រសួងបរិស្ថាន ជួយពិនិត្យមើល**រមណីយដ្ឋាននៅតាមមាត់ទឹក** ដូចជានៅកៀនស្វាយជាដើម។

## អ្នកតំណាងរាស្ត្រស្នើរដ្ឋមន្ត្រីក្រសួងមហាផ្ទៃមកបំភ្លឺនៅសភា



អ្នកតំណាងរាស្ត្រ **យឹម សុវណ្ណ** មណ្ឌលភ្នំពេញ និងជាប្រធានគណៈកម្មការទី៤ រដ្ឋសភា បានស្នើសុំរដ្ឋមន្ត្រីក្រសួងមហាផ្ទៃមកបំភ្លឺ ចំពោះសភាពេញអង្គ ពីករណីប្រើអំពើហិង្សាបង្ក្រាបលើបាតុកម្ម កូដកម្ម និងក្បួនដង្ហែផ្សេងៗដោយសន្តិវិធី។ ក្នុងលិខិតដាក់ជូនសម្តេចអគ្គ មហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា អ្នកតំណាងរាស្ត្រ **យឹម សុវណ្ណ** បានឱ្យដឹងថា **កងកម្លាំងប៉ូលីសបាននិងកំពុងប្រើប្រាស់អំពើហិង្សាបង្ក្រាប ទៅលើព្រះសង្ឃ ប្រជាពលរដ្ឋ និងសង្គមស៊ីវិល**ដែលបានចូលរួមក្នុងបាតុកម្ម កូដកម្ម និងក្បួនដង្ហែផ្សេងៗ ។ ក្នុងលិខិតនោះក៏បានលើកឡើងផងដែរ ពីការបង្ក្រាបរបស់កងកម្លាំងប្រដាប់អាវុធដោយប្រើដំបងឆក់ និងវាយដំទៅលើ ព្រះសង្ឃខ្មែរ កម្ពុជាក្រោមមួយក្រុមដែលបាននិមន្តក្បួនដង្ហែដោយ សន្តិវិធីដើម្បីនាំយកញត្តិសម្តែងមតិ ទាមទារឱ្យមានការគោរពសិទ្ធិមនុស្សនៅកម្ពុជាក្រោម ទៅជូនស្ថានទូតវៀតណាមនៅទីក្រុងភ្នំពេញ។ ទោះបីយ៉ាងណា ខុមហ្វ្រែលមិនទាន់បានទទួលព័ត៌មានពីការឆ្លើយតបពីរាជរដ្ឋាភិបាលនៅឡើយទេ។

## ការអនុម័តនានាដោយរដ្ឋសភា

នៅក្នុងសម័យប្រជុំពេញអង្គដែលមានរយៈពេល ១៧ព្រឹក រដ្ឋសភាបានពិភាក្សា និងអនុម័តរបៀបវារៈសំខាន់ចំនួន ១៥ ដែលក្នុងនោះរួមមាន សេចក្តីព្រាងច្បាប់ សេចក្តីស្នើច្បាប់ ការបោះឆ្នោតជ្រើសតាំងសមាជិកគណៈកម្មការជំនាញសភា ការប្រកាសសុពលភាពរបស់អ្នកតំណាងរាស្ត្រថ្មី និង របៀបវារៈផ្សេងៗទៀត។ ខាងក្រោមនេះ គឺជាសេចក្តីព្រាងច្បាប់ៗមួយចំនួនដែលសភាបានអនុម័ត និងសម្រេច:

- សេចក្តីព្រាងច្បាប់ស្តីពីការអនុម័តយល់ព្រមលើធម្មនុញ្ញអាស៊ាន
- សេចក្តីព្រាងច្បាប់ស្តីពីនីតិវិធីនៃការពិន័យស៊ីវិល
- សេចក្តីព្រាងច្បាប់ធម្មនុញ្ញស្តីពីវិសោធនកម្មមាត្រា ១៤៥ថ្មី និង ១៤៦ថ្មី នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។
- សេចក្តីព្រាងច្បាប់ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ ២០០៥
- សេចក្តីព្រាងច្បាប់ស្តីពីអាកាសចរស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- សេចក្តីស្នើច្បាប់ស្តីពីលក្ខន្តិកៈសមាជិកព្រឹទ្ធសភា
- សេចក្តីព្រាងច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ
- សេចក្តីព្រាងច្បាប់ស្តីពីតំបន់ការពារធម្មជាតិ
- សេចក្តីព្រាងច្បាប់ស្តីពីជីវសុវត្ថិភាព

# កាលប្បវត្តិព្រឹត្តិការណ៍សំខាន់ៗ ពី ពាក់កណ្តាលខែធ្នូ ឆ្នាំ២០០៧ ដល់ពាក់កណ្តាលខែមីនា ២០០៨

## នយោបាយ

- **៣០ ធ្នូ ២០០៧** : សម្តេចក្រុមព្រះនរោត្តម រណឫទ្ធិ ប្រធានគណបក្សនរោត្តម រណឫទ្ធិ បានមានបន្ទូលតាមរយៈទូរស័ព្ទពីប្រទេសម៉ាឡេស៊ីក្នុងឱកាសជួបសំណេះសំណាលជាមួយសមាជិកគណបក្សនៅក្រុងភ្នំពេញថាព្រះអង្គនឹងលា ជាតិពីស្តេចទៅជារាស្ត្រសាមញ្ញវិញ នៅពេលដែលពលរដ្ឋខ្មែរនៅតែវេទនាដូចបច្ចុប្បន្ននេះ ដើម្បី បន្តធ្វើនយោបាយ ។
- **១៣ មករា ២០០៨** : គណបក្សប្រជាជនកម្ពុជា បានប្រកាសបេក្ខភាពសម្តេចតេជោ ហ៊ុន សែន សំរាប់តំណែងនាយករដ្ឋមន្ត្រីអាណត្តិទី៤ ជាថ្មី និងសន្យាបន្តរដ្ឋាភិបាលចំរុះជាមួយគណបក្សហ៊ុនស៊ិនប៉ិច ។
- **២៧ មករា** : គណបក្ស សម រង្ស៊ីបានប្រកាសដកលោក គៀង វ៉ាង អតីតតំណាងរាស្ត្រគណបក្ស សម រង្ស៊ី មណ្ឌលខេត្តកំពតបន្ទាប់ពីសមាជិកគណបក្សសម រង្ស៊ីក្នុងខេត្តកំពតបានរាយការណ៍ថា លោកបាន ធ្វើយុទ្ធនាការ ឱ្យគណបក្ស ហ៊្វុនស៊ិនប៉ិច ហើយដាក់ជំនួសដោយលោក វ៉ាន់ ដារ៉ា សមាជិកក្រុមប្រឹក្សា ខេត្តកំពតរបស់គណបក្សសម រង្ស៊ី។ **ថ្ងៃទី ៤ កុម្ភៈ** : សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន បានប្រកាសថា គណបក្សប្រជាជនកម្ពុជានឹងស្វាគមន៍ ក្រុមអ្នកផ្តាច់ ខ្លួនមកពីបណ្តាគណបក្សនយោបាយដទៃទៀត ។ មិនតែប៉ុណ្ណោះអ្នកទាំងនោះត្រូវបានទទួលការតែងតាំងជាទីប្រឹក្សា រាជរដ្ឋាភិបាលមានឋានៈស្មើរដ្ឋមន្ត្រីឬ រដ្ឋលេខាធិការ ក្នុងនោះរួមមានដូចជា លោក **ង៉ោ សុវណ្ណ** លោក **សុខ ផេង** លោក **ចៅ ផល្លី** និងលោក **ឈិត សារិទ្ធ** ជាដើមដែលសុទ្ធតែជាអតីតតំណាងរាស្ត្រ និងសមាជិកក្រុមប្រឹក្សានាយក គណបក្ស សម រង្ស៊ី។ ជុំវិញការតែងតាំងនេះ នៅ ថ្ងៃទី **២០ ខែ កុម្ភៈ** លោក **សុន ឆ័យ** សមាជិកសភាគណបក្ស សម រង្ស៊ី បានបញ្ជូនសំណើផ្លូវការទៅសម្តេចនាយករដ្ឋមន្ត្រី **ហ៊ុន សែន** ស្នើសុំឱ្យបញ្ឈប់ការតែងតាំងនេះ ដោយបាន លើកថាមិនស្របនឹងច្បាប់ និងចំណាយថវិការដ្ឋខ្ជះខ្ជាយ ។ លោក សុន ឆ័យ ក៏បានស្នើឱ្យ រដ្ឋាភិបាលផ្តល់ នូវបញ្ជីឈ្មោះរបស់អ្នកដែលជាទីប្រឹក្សាទាំងឡាយមករដ្ឋសភា។ **នៅថ្ងៃ ២១ កុម្ភៈ** សម្តេច នាយករដ្ឋមន្ត្រី **ហ៊ុន សែន** បានវាយបក ត្រឡប់ទៅនឹងការរិះគន់នេះ ដោយបានប្រកាសថានឹងតែងតាំង មនុស្សជាច្រើនទៀតនៅពេល សម្តេចមើលឃើញថា ស័ក្តិសម ។ ទន្ទឹមនឹងការចាកចេញជាបន្តបន្ទាប់របស់ សមាជិកសំខាន់នៃគណបក្សសម រង្ស៊ី មកចូលរួមជាមួយគណបក្ស ប្រជាជននេះ **នៅថ្ងៃទី ៤ មីនា លោក នូវ សុវត្ថិ** អតីតអ្នកនាំពាក្យគណបក្សហ៊្វុនស៊ិនប៉ិច បានចាកចេញពីគណបក្សនេះដែរ ហើយមានគំរោងចូលរួមជាមួយគណបក្សប្រជាជនកម្ពុជាដែរ ។
- **២៧ កុម្ភៈ** : ប្រធានគណបក្សសិទ្ធិមនុស្ស លោក **កឹម សុខា** ត្រូវបានសមាជគណបក្សជ្រើសរើសជាបេក្ខជននាយក រដ្ឋមន្ត្រីសំរាប់ការបោះឆ្នោតឆ្នាំ២០០៨នេះ ។
- **ថ្ងៃទី ០៨ មីនា** : សម្តេចនាយករដ្ឋមន្ត្រី **ហ៊ុន សែន** បានមានស្រាសន៍ឆ្លើយតបទៅនឹងសេចក្តីស្នើរបស់ ប្រធានគណបក្សសិទ្ធិមនុស្សគឺលោក **កឹម សុខា** ដែលទាមទារឱ្យមានការជជែកទល់មុខគ្នារវាងបេក្ខជន នាយករដ្ឋមន្ត្រី មកពីគណបក្សនានាតាមប្រព័ន្ធផ្សព្វផ្សាយ គឺមិនមានការចាំបាច់ទេ។ សម្តេចបានបញ្ជាក់ថា ការបោះឆ្នោតនៅសហរដ្ឋអាមេរិក ឬបារាំងគេបោះឆ្នោតរើសប្រធានាធិបតីតាមបែបឯកត្តនាម ។ តែសំរាប់ កម្ពុជា ការបោះឆ្នោតបែបសមាមាត្រគណបក្សណាឈ្នះទើបតែងតាំងនាយករដ្ឋមន្ត្រី ។
- **១០ មីនា** : គណបក្សនរោត្តម រណឫទ្ធិ បានធ្វើការអំពាវនាវរបស់ខ្លួនសារជាថ្មី ឱ្យគណបក្សសិទ្ធិមនុស្ស និងគណបក្ស សម រង្ស៊ី រួបរួមកំលាំជាមួយគណបក្ស នរោត្តម រណឫទ្ធី មុនការបោះឆ្នាតជាតិ២០០៨។
- **១៩ មីនា** : ព្រះអង្គម្ចាស់ស៊ីសុវត្ថិ ធម្មិកោ បានធ្វើការចោទប្រកាន់ទៅដល់គណបក្សនយោបាយប្រឆាំងធំៗ នៅកម្ពុជាថាគ្មានបំណងប្រកួតប្រជែងតទល់ជាមួយគណបក្សប្រជាជនកម្ពុជាទេ តាមពិតពួកគេកំពុងតែប្រកួតគ្នា ដើម្បីចូលមកធ្វើជាដៃគូជាមួយគណបក្សកាន់អំណាចនៅក្រោយការបោះឆ្នោតថ្នាក់ជាតិ២០០៨។

## សិទ្ធិមនុស្ស និងប្រជាធិបតេយ្យ

- **០១ មករា** : សេចក្តីថ្លែងការណ៍របស់ក្រសួងព័ត៌មានបានគាំទ្រនូវការទាមទាររបស់វេទិកានិពន្ធនាយក សារព័ត៌មានកម្ពុជា

(វ.ន.ស.ក) ដែលសុំឱ្យប្រើប្រាស់ច្បាប់ស្តីពីរបបសារព័ត៌មាននៅក្នុងរឿងទាំងឡាយណាដែល ទាក់ទងនឹងការងាររបស់ សារព័ត៌មានលើកលែងតែការចោទប្រកាន់ណាដែលជាការប្រព្រឹត្តិរបស់បុគ្គលក្រៅ រង្វង់សារព័ត៌មាន ។

- **២០ មករា :** តំណាងសង្គមស៊ីវិលប្រមាណជាង ១០០នាក់បានប្រមូលផ្តុំគ្នានៅច្រកចូលទៅសារមន្ទីរ ប្រល័យពូជសាសន៍ទួលស្លែង ដែលដឹកនាំដោយកញ្ញា **សេង ធារី** នាយិកាមជ្ឈមណ្ឌលអភិវឌ្ឍន៍សង្គម រួមជាមួយតារាភាពយន្តអាមេរិក នាង **Mia Farrow** ដើម្បីប្រារព្ធពិធីគោរពដល់ជនរងគ្រោះនៅតំបន់ដាហ្វួរ និងអ្នករស់រានមានជីវិតពីរបបប៉ុលពត ប៉ុន្តែត្រូវបានរារាំង ដោយអាជ្ញាធរមានសមត្ថកិច្ចដោយអះអាងថា មិនមានការអនុញ្ញាតពីរាជរដ្ឋាភិបាលទេ ។
- **២៨ មករា :** សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន បានមានប្រសាសន៍ថាអង្គការសហប្រជាជាតិអាចនឹងធ្វើការ បានល្អជាជាងចំណាយទៅលើការងាររបស់បេសកជន សិទ្ធិមនុស្សប្រចាំកម្ពុជា គឺលោក យ៉ាស ហ្គាយ ។ សម្តេច បាន មានប្រសាសន៍ថា *"អ្នកតំណាងរបស់អង្គការសហប្រជាជាតិគួរតែប្រមូលថវិការបស់ ពួកគេទាំងអស់សំរាប់ចំណាយ ក្នុងប្រទេសកេន យ៉ា ស៊ូដង់ សូម៉ាលី អ៊ីរ៉ាក់ និងអាហ្គានីស្ថាន"* ។ សម្តេច ហ៊ុន សែនបានថ្លែងថា ថ្វីបើលោក ហ្គាយ មិនអាចទទួលប្រាក់ខែរបស់អង្គការសហប្រជាជាតិក៏ដោយ ក៏អង្គការនេះនៅតែ ចំណាយសោហ៊ុយដល់គាត់ដែរ ។
- **១៣ កុម្ភៈ :** ប្រទេសកម្ពុជាបានច្រានចោលរបាយការណ៍របស់សហរដ្ឋអាមេរិកស្តីពីការគោរពសិទ្ធិមនុស្ស ដោយ និយាយថារបាយការណ៍ប្រចាំឆ្នាំរបស់សភាអាមេរិក" ផ្ទុយស្រឡះពីភាពពិតនៅក្នុងប្រទេស" ។
- **១៤ កុម្ភៈ :** ក្រសួងការបរទេសបានបដិសេធជាផ្លូវការចំពោះការចោទប្រកាន់នាពេលកន្លង របស់អង្គការ លើកលែងទោសអន្តរជាតិដែលថា រដ្ឋាភិបាលជាប់ពាក់ព័ន្ធនៅក្នុងការបណ្តេញចេញប្រជាជនរាប់ពាន់អ្នក ដោយបង្ខំខុសច្បាប់ ។ សេចក្តីថ្លែងការណ៍របស់ក្រសួងការបរទេសបានឆ្លើយតបដោយសំដែងការសោកស្តាយ និងលើកឡើងថា អង្គការលើកលែងទោសអន្តរជាតិបានបំផ្លើសស្ថានភាព និងប្រឌិតការពិតនៅក្នុងប្រទេសកម្ពុជា ព្រោះយើងគ្មានការបណ្តេញ ចេញដោយបង្ខំ និងខុសច្បាប់នោះទេ ប៉ុន្តែវាអាចមានការចាំបាច់ម្តងម្កាល ក្នុងការរៀបចំសណ្តាប់ធ្នាប់សាធារណៈអាជ្ញាធរអាចបណ្តេញប្រជាជនដែលកាន់កាប់ដីរដ្ឋខុសច្បាប់ ។

## *ការបោះឆ្នោត*

- **០១ មីនា :** សហគមន៍អឺរ៉ុបគ្រោងបញ្ជូនអ្នកសង្កេតការណ៍ចំនួន១៥០ ទៅ២០០នាក់មកកាន់កម្ពុជាដើម្បីពិនិត្យ មើលដំណើរការបោះឆ្នោតនាពេលខាងមុខ ។
- **២៧ កុម្ភៈ :** គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត គ.ជ.ប បានរៀបចំសន្និសីទសាពត៌មាន ផ្សព្វផ្សាយ បញ្ជីបោះឆ្នោតផ្លូវការ និងការផ្តល់អនុសាសន៍ដែលទាក់ទងនឹងសេចក្តីព្រាងបទបញ្ជា និងនីតិវិធី ។ បញ្ជីបោះឆ្នោតមាន ចំនួនអ្នកបោះឆ្នោតសរុប ៨.១២៤.០៩២ នាក់ ហើយមានការិយាល័យបោះឆ្នោតចំនួន ១៥.២៥៤ ការិយាល័យ ។ ក្នុងថ្ងៃនេះដែរ គ.ជ.ប ក៏បានចេញសេចក្តីជូនដំណឹងអំពីឈ្មោះអ្នកបោះឆ្នោតជាង ៨លាននាក់បានផ្សព្វផ្សាយតាមវិសាយគ.ជ.ប www.voterlist.org.kh ។
- **២៩ កុម្ភៈ :** ខុមហ្វ្រែលចេញសេចក្តីប្រកាសពតិមានស្តីពីលទ្ធផលនៃការអង្កេតទៅលើទូរទស្សន៍ជាតិកម្ពុជា (ទទក) ដោយចាប់ពីខែតុលា២០០៧ ដល់ខែមករា២០០៨ ។ លទ្ធផលបង្ហាញថាពតិមាននយោបាយនៅក្នុង ទទក មិនមានកាប្រែប្រួលខុសប្លែកពីរបាយការណ៍អង្កេតមុនៗនោះទេ ដោយពតិមានភាគច្រើនសំរាប់តែ គណបក្សប្រជាជនកម្ពុជាកាន់អំណាចប៉ុណ្ណោះ ។ ចំណែក គណបក្ស ហ្វុនស៊ិនប៉ិច និងគណបក្ស សម រង្ស៊ី ត្រូវបានឮតិចតួចនៅ ក្នុងរយៈពេលអង្កេតនេះ ។
- **១១ មីនា :** គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត គ.ជ.ប បានចេញប្រកាសឱ្យប្រើជាផ្លូវការនូវ បទបញ្ជា និងនីតិវិធីសំរាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រអាណត្តិទី៤ ផ្នែកទី២ ដែលមានជំពូកទី៧ ទី៨ ទី៩ ទី១០ ទី១១ ទី១២ និងមានឧបសម្ព័ន្ធចំនួន៦ ។ បទបញ្ជា និងនីតិវិធីនេះក៏នឹងដាក់បញ្ចូលផងដែរនៅលើ វេបសាយរបស់គ.ជ.ប www.necelect.org.kh ។

## *ច្បាប់ និងប្រព័ន្ធយុត្តិធម៌*

- **០៨ មករា :** មន្ត្រីតុលាការចំនួយ ៣៧រូប ត្រូវបានផ្ទេរភារកិច្ចរបស់ខ្លួនតាមព្រះរាជក្រឹត្យចុះថ្ងៃទី៣០ធ្នូ ឆ្នាំ២០០៧ ដើម្បីទៅបំរើការងារនៅតាមស្ថាប័នតុលាការខេត្តក្រុងទូទាំងប្រទេស ។ មន្ត្រីតុលាការជាចៅក្រម និងព្រះរាជអាជ្ញាត្រូវ បានផ្ទេរក្នុងនោះមន្ត្រីខ្លះជាប្រធានតុលាការ ព្រះរាជអាជ្ញា និងព្រះរាជអាជ្ញារង ។
- **០៧ កុម្ភៈ :** រដ្ឋសភាបានបញ្ជូនសេចក្តីព្រាងច្បាប់ថ្មីស្តីពីការធ្វើបាតុកម្មត្រឡប់ទៅរដ្ឋាភិបាលវិញ បន្ទាប់ពីមានការរិះគន់ ទៅ

លើការអនុម័តរបស់គណៈរដ្ឋមន្ត្រីដើម្បីកែប្រែទំរង់ខ្លឹមសារខ្លះៗ ព្រោះសេចក្តីព្រាងនេះ សមាជិកសភាជាច្រើនបានជំទាស់ទៅនឹងមាត្រាមួយចំនួនដែលមានភាពចំរូងចំរាសជាពិសេសមាត្រា២៦ ដែលចែងអំពីការទទួលខុសត្រូវរបស់អ្នក ដឹកនាំធ្វើបាតុកម្ម ។

- **២៧ កុម្ភៈ :** ក្រុមចៅក្រម សហព្រះរាជអាជ្ញានៃសាលាក្តីខ្មែរក្រហម បាននាំខ្លួនឌុច អតីតមេគុកទួលស្លែងទៅកន្លែង ដែលគាត់ធ្លាប់ធ្វើការកាលពីរបបខ្មែរក្រហម ក្រោមការរឹតបន្តឹងសន្តិសុខយ៉ាងខ្លាំងបំផុតពីក្រុមប៉ូលីស រហូតមានការ មិនពេញចិត្តពីក្រុមអ្នកសារព័ត៌មានដែលត្រូវហាមឃាត់មិនឱ្យថតយករូបភាពផ្សព្វផ្សាយ ។

## *អភិបាលកិច្ច*

- **១៤ មករា :** គណបក្ស ហ៊ុនស៊ិនប៉ិចបានចូលរួមជាមួយគណបក្ស សម រង្ស៊ីសំដែងកង្វល់នៅរដ្ឋសភា ស្តីពីវិសោធនកម្ម លើរដ្ឋធម្មនុញ្ញជាមួយនិងសេចក្តីព្រាងច្បាប់គ្រប់គ្រងរដ្ឋបាលដែលនឹងបង្កើតអង្គនីតិប្បញ្ញត្តិថ្មីនៅថ្នាក់ខេត្តក្រុងនិងថ្នាក់ខណ្ឌស្រុក ។ លោក **ញឹក ប៊ុនឆៃ** បានមានប្រសាសន៍ "យើងចង់ឱ្យមានការ បោះឆ្នោតជ្រើសរើសអភិបាលក្រុង ដូចបណ្តាលប្រទេសដទៃទៀត យើងត្រូវតែធ្វើការបោះឆ្នោតជាសកល" ។ ឯលោក **សម រង្ស៊ី** បានមានប្រសាសន៍ថា ដើម្បីធ្វើវិសោធនកម្មមាត្រាណាមួយនៃរដ្ឋធម្មនុញ្ញរបស់ព្រះរាជាណាចក្រកម្ពុជា ត្រូវតែមានការពិភាក្សាជាមុនរវាងគណបក្សនានា ។
- **១៥ មករា :** រដ្ឋសភា បានអនុម័តការកែប្រែមាត្រា១៤៥ និង១៤៥ ថ្មី របស់រដ្ឋធម្មនុញ្ញ ដោយបើកទ្វារឱ្យរៀបចំឡើងវិញនូវព្រំដែនរដ្ឋបាល បង្កើតច្បាប់គ្រប់គ្រងរដ្ឋបាល បង្កើតអង្គភាពដែលគេ បោះឆ្នោតជ្រើសរើស ថ្មីនៅថ្នាក់ខេត្ត-ក្រុង និងខណ្ឌស្រុក ។

## *ការអភិវឌ្ឍ*

- **១៦ មករា :** ថ្លែងនៅក្នុងរដ្ឋសភាជាតិ លោក **គាត ឈន់** រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានលើកឡើងថា សេដ្ឋកិច្ចកម្ពុជាមានការកើនឡើង ប្រាក់ចំណូលប្រចាំឆ្នាំជាមធ្យមបានកើនឡើងស្មើរតែ ៩% នៅក្នុងប្រទេស ដោយកើនឡើងពីប្រាក់ចំណូល ប្រចាំឆ្នាំជាមធ្យម ៦១៣ ដុល្លារក្នុងឆ្នាំ២០០៦ ដល់៦៨៩ ដុល្លារក្នុងឆ្នាំ២០០៧ ។
- **១៣ មីនា :** សម្តេចនាយករដ្ឋមន្ត្រី **ហ៊ុន សែន** បានបញ្ជាឱ្យក្រុមមន្ត្រីរដ្ឋាភិបាលនៅទូទាំង ប្រទេសចាត់វិធានការ សន្សំសំចៃភ្លើងអគ្គិសនីឱ្យតឹងរ៉ឹង ជាការសន្សំសំចៃមួយឈានដល់ការបិទអំពូលភ្លើងតាមផ្លូវទៀតផង ។ តាមសារាចរណ៍ ណែនាំមួយរបស់រដ្ឋាភិបាលបានបង្ហាញថា រដ្ឋាភិបាលមានផែនការចំណាយប្រាក់២៤លាន ដុល្លារដល់ក្រុមហ៊ុនអគ្គិសនី កម្ពុជារបស់រដ្ឋជាការប្រឹងប្រែងរក្សាតំលៃអគ្គិសនីកុំឱ្យឡើងថ្លៃ ។


**គណៈកម្មការព្រឹត្តិបត្រ**

1- elak **គល់ បញ្ញា** TRbkSapleyabl
2- elak **ចំនួ ជារិទ្ធ** RbFansRmbsRml Btman ngkarpSay
3- elak **កាំង សុវណ្ណារេន** mRnsRmbsRmlkar nBnng RBtbRt
4- kBaa **រស់ ស៊ីណាក់** smaCk

Gasydan
pHelx 138 pv 122 sgatTklk1
xNTleKak raCFanPeBj kmCa
RbGbsbRt 1145



TrsB 023 884 150
Trsar 023 883 750
Geml **comfrel@online.com.kh**
eKhTBr **www.comfrel.org**


បើលោក អ្នកនាងកញ្ញាមានសំណួមពរ ចម្ងល់ ឬមានបំណងចូលរួមយោបល់ ឬស្នើសុំព្រិត្តិបត្រសម្រាប់ស្ថាប័ន សូមទាក់ទងមកកាន់យើងខ្ញុំតាមរយៈអាសយដ្ឋានខាងលើនេះ។

**ព្រឹត្តិបត្រ "អ្នកឃ្លាំមើល" ពីអង្គការសមាគម-មិនមែនរដ្ឋាភិបាល នៅដល់ដៃប្រជាពលរដ្ឋនៅទូទាំងប្រទេស ដើម្បីភ្ជាប់ចន្លោះព័ត៌មានរវាងប្រជាពលរដ្ឋ និងអ្នកតំណាង និងអ្នកដឹកនាំពាក់ព័ន្ធក្នុងការចូលរួមស្ថាបនាសង្គមប្រជាធិបតេយ្យ ។**

# សកម្មភាពការងាររបស់គណៈកម្មាធិការខុមហ្វ្រែល



គណប្រតិភូខុមហ្វ្រែលជួបពិភាក្សាការងារជាមួយនឹងថ្នាក់ដឹកនាំគណបក្សហ្វ៊ុនស៊ិនប៉ិច



គណប្រតិភូខុមហ្វ្រែលជួបពិភាក្សាការងារជាមួយនឹងថ្នាក់ដឹកនាំគណបក្សសមរង្ស៊ី



គណប្រតិភូខុមហ្វ្រែលជួបពិភាក្សាការងារជាមួយនឹងថ្នាក់ដឹកនាំគណបក្សប្រជាជនកម្ពុជា



គណប្រតិភូខុមហ្វ្រែលជួបពិភាក្សាការងារជាមួយនឹងថ្នាក់ដឹកនាំគណបក្សនរោត្តមរណឫទ្ធិ